ស្ថាបនា លីមីតធីត

SATHAPANA LIMITED

MARUHAN JAPAN GROUP

# របាយការណ៍ប្រចាំឆ្នាំ ២០១៥









គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេក្នុងព្រះរាជាណាចក្រកម្ពុជា

# ចក្ខុវិស័យ និង បេសកកម្ម



## ចក្ខុវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុដែលឈានមុខគេក្នុងការកសាងសហគ្រិន
ក្នុងសហគមន៍អាស៊ីអាគ្នេយ៍។

## បេសកកម្ម

បំពាក់សក្តានុពលដល់សហគ្រិន និងបង្កើត ការងារសំដៅលើកកំពស់ជីវភាពរស់នៅ
របស់ពួកគាត់តាមរយៈការទទួលបានសេវាកម្មហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។

# មាតិកា


**ចក្ខុវិស័យ និង បេសកកម្ម** i

**មាតិកា** ii

គន្លឹះសូចនាករប្រតិបត្តិការ ០១

តំបន់ប្រតិបត្តិការ ០២

ប្រវត្តិរូបសង្ខេប និងរចនាសម្ព័ន្ធ ០៣

ប្រវត្តិសង្ខេប ០៤

សារប្រធានក្រុមប្រឹក្សាភិបាល ១១

សារប្រធាននាយកប្រតិបត្តិ ១៣

ក្រុមប្រឹក្សាភិបាល ១៥

ថ្នាក់ដឹកនាំជាន់ខ្ពស់ ២០

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ២២

ម្ចាស់ភាគហ៊ុន ២៦

ភាពជាដៃគូ និងបណ្តាញទំនាក់ទំនង ២៧

ការត្រួតពិនិត្យអាជីវកម្មផ្នែកប្រតិបត្តិការ ៣០

- សមិទ្ធិផលសម្រេចបាន ៣០
- បុគ្គលិក និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ៣២

ការគ្រប់គ្រងហានិភ័យ និង ប្រតិបត្តិតាម ៣៣

សកម្មភាពសង្គម ៣៤

និរន្តរភាពសង្គម និងបរិស្ថាន ៣៦

របាយការណ៍សវនករឯករាជ្យ ៣៩

តារាងតុល្យការ ៤១

របាយការណ៍លទ្ធផល ៤២

របាយការណ៍បំរែបំរួលមូលធន ៤៣

របាយការណ៍លំហូរសាច់ប្រាក់ ៤៤

ប្រាក់កម្ចី ៤៥

ដើមទុន ៤៦

បណ្តាញសាខា ៤៧

អាសយដ្ឋានសាខា ៤៨

# គន្លឹះសូចនាករប្រតិបត្តិការ

| តារាងស្តីពីកំណើន និងសូចនាករប្រតិបត្តិការគន្លឹះរបស់ ស្ថាបនា លីមីតធីត (2011-2015) | | | | | |
|---|---|---|---|---|---|
| | **31-12-11** | **31-12-12** | **31-12-13** | **31-12-14** | **31-12-15** |
| សរុបនៃការបញ្ចេញឥណទាននៃពេលនីមួយៗ | $121,366,900 | $149,776,743 | $216,030,440 | $349,115,416 | $488,011,548 |
| ផលប័ត្រឥណទាន | 88%<br>$94,665,480 | 81%<br>$121,341,881 | 87%<br>$181,589,769 | 86%<br>$311,393,541 | 88%<br>$472,018,731 |
| អត្រាកំណើនផលប័ត្រឥណទាន | 64% | 28% | 50% | 71% | 52% |
| ផលប័ត្រឥណទានសុទ្ធ | $94,268,106 | $120,626,698 | $180,845,353 | $310,289,536 | $470,335,543 |
| សមតុល្យប្រាក់បញ្ញើ-សន្សំ | $38,891,904 | $66,710,094 | $80,586,269 | $166,096,268 | $259,870,588 |
| អត្រាកំណើនប្រាក់បញ្ញើ-សន្សំ | 129% | 72% | 21% | 106% | 56% |
| សន្ទនិយភាព( សាច់ប្រាក់ក្នុងដៃ និងក្នុងធនាគារ ) | 7%<br>$7,328,924 | 15%<br>$22,291,751 | 9%<br>$18,842,049 | 11%<br>$39,591,974 | 9%<br>$50,598,899 |
| ទ្រព្យសម្បត្តិរយៈពេលវែង / ជាប់លាប់បានយូរ | 3.6%<br>$3,924,295 | 2.4%<br>$3,598,127 | 1.9%<br>$4,053,660 | 1.2%<br>$4,241,654 | 1.0%<br>$5,557,653 |
| ទ្រព្យសកម្មសរុប | $107,926,524 | $149,615,423 | $209,106,468 | $362,535,957 | $539,088,013 |
| **គុណភាពឥណទាន** | | | | | |
| 1/ ហានិភ័យឥណទាន (>30ថ្ងៃ) | 0.22%<br>$207,708 | 0.39%<br>$473,499 | 0.21%<br>$381,998 | 0.15%<br>$482,182 | 0.16%<br>$736,684 |
| 2/ ការសងត្រឡប់ទាន់ពេល | 99.83%<br>$159,281 | 99.78%<br>$262,460 | 99.86%<br>$258,639 | 99.95%<br>$145,812 | 99.99%<br>$58,158 |
| 3/ អនុបាតឥណទានលុបចេញពីបញ្ជី | 0.33% | 0.00% | 0.18% | 0.10% | 0.04% |
| **រចនាសម្ព័ន្ធថ្លៃដើម (ថ្លៃដើម/ជាមធ្យម)** | | | | | |
| 1/ អនុបាតប្រាក់បៀវត្ស (និងប្រាក់លើកទឹកចិត្ត) | 6.57% | 6.85% | 6.00% | 4.85% | 4.28% |
| 2/ អនុបាតរដ្ឋបាល | 4.76% | 5.37% | 4.50% | 3.56% | 3.07% |
| 3/ អនុបាតប្រភពទុន | 7.30% | 7.65% | 7.22% | 7.14% | 8.06% |
| ថ្លៃដើមសរុប | 18.64% | 19.87% | 17.73% | 15.55% | 15.41% |
| **ផលិតភាព** | | | | | |
| 1/ ផលប័ត្រឥណទានក្នុងមន្ត្រីឥណទានម្នាក់ | $168,145 | $165,541 | $198,242 | $305,587 | $373,433 |
| 2/ ចំនួនអ្នកខ្ចីក្នុងភ្នាក់ងារឥណទានម្នាក់ | 101 | 93 | 86 | 93 | 89 |
| **លទ្ធភាពប្រាក់ចំណេញ** | | | | | |
| 1/ ផលត្រឡប់នៃដើមទុន | 25.56% | 20.57% | 25.57% | 29.82% | 35.96% |
| 2/ ផលត្រឡប់នៃទ្រព្យសកម្ម | 3.78% | 3.11% | 3.40% | 3.70% | 4.20% |
| 3/ ស្វ័យគ្រប់គ្រាន់នៃប្រភពហិរញ្ញវត្ថុ (សរុបចំណូល / ចំណាយ) | 130% | 124% | 126% | 134% | 139% |
| **ព័ត៌មានលំអិតអំពីបុគ្គលិក និងអតិថិជន** | | | | | |
| បុគ្គលិក | 1,339 | 1,710 | 2,147 | 2,469 | 3,123 |
| អត្រាកំណើនបុគ្គលិក | 39% | 28% | 26% | 15% | 26% |
| ភ្នាក់ងារឥណទាន | 563 | 733 | 916 | 1,019 | 1,264 |
| អតិថិជនប្រាក់កម្ចី | 57,001 | 68,195 | 78,862 | 94,852 | 112,684 |
| កំណើនអតិថិជនប្រាក់កម្ចី | 31% | 20% | 16% | 20% | 19% |
| អតិថិជនប្រាក់បញ្ញើសន្សំ | 39,660 | 47,676 | 58,157 | 87,552 | 127,900 |
| កំណើនអតិថិជនប្រាក់បញ្ញើសន្សំ | 22% | 20% | 22% | 51% | 46% |
| ប្រាក់ចំណូលសរុប | $18,428,754 | $26,520,597 | $33,800,375 | $51,556,922 | $84,005,066 |
| ដើមទុនសរុប | $17,612,342 | $21,282,408 | $26,374,360 | $44,521,671 | $60,819,883 |
| អត្រាចំណេញជាមធ្យមនៃផលប័ត្រ | 24.18% | 24.56% | 22.32% | 20.92% | 20.30% |

# តំបន់ប្រតិបត្តិការ




## គ្របដណ្ដប់

| | | |
|---|---|---|
| ខេត្ត | : | ២៥ |
| ស្រុក | : | ១៩៣ |
| ឃុំ | : | ១.៦០៤ |
| ភូមិ | : | ១០.២៦៨ |
| ទ្រព្យសកម្មសរុប | : | US$ ៥៣៩.០៨៨.០១៣ |
| សមតុល្យឥណទាន | : | US$ ៤៧២.០១៨.៧៣១ |
| បញ្ញើ-សន្សំ | : | US$ ២៥៩.៨៧០.៥៨៨ |

## បណ្ដាញសាខាទូទាំងប្រទេស

| | | |
|---|---|---|
| ការិយាល័យកណ្ដាល | : | ០១ |
| សាខា (ក) | : | ៩៥ |
| សាខា (ខ) | : | ៥៣ |
| សាខាសរុប | : | ១៤៩ |
| អេធីអឹមសរុប | : | ៦២ |

# ប្រវត្តិរូបសង្ខេប

| | | |
|---|---|---|
| ឈ្មោះក្រុមហ៊ុន | : | ស្ថាបនា លីមីតធីត |
| អាសយដ្ឋាន | : | អគារលេខ៨៣១C វិថីព្រះមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ទូរស័ព្ទទំនាក់ទំនង | : | ០៩៧ ៩៥៧ ៦៦៦៦ / ០៩៦ ៩២២ ៧៧៧៧ |
| អ៊ីម៉ែល | : | info@sathapana.com.kh |
| គេហទំព័រ | : | www.sathapana.com.kh |
| ឆ្នាំនៃការបង្កើត | : | ១៩៩៥ |
| ចំនួនបុគ្គលិកសរុប | : | ៣.១២៣ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥) |
| ភាគទុនិក | : | MARUHAN Japan Bank Plc. |

## រចនាសម្ព័ន្ធ



# ប្រវត្តិសង្ខេប

**ស្ថាបនា លីមីតធីត** ត្រូវបានបង្កើតឡើងក្នុងលក្ខណៈជាអង្គការក្រៅរដ្ឋាភិបាលនៅក្នុងឆ្នាំ ១៩៩៥ ក្រោមឈ្មោះថា ស្ថាបនាសហគមន៍កម្ពុជា (ហៅកាត់ថា CCB) ដោយផ្តល់សេវាកម្មអប់រំផ្នែកសុខភាព និងហិរញ្ញវត្ថុដល់សហគមន៍ក្រីក្រ។ បន្ទាប់ពីប្រាក់ជំនួយត្រូវបានបញ្ចប់នៅចុងឆ្នាំ ១៩៩៩ ស្ថាបនាសហគមន៍កម្ពុជា បានអនុវត្តវិធីសាស្រ្តមីក្រូហិរញ្ញវត្ថុតូចមួយ ផ្តោតទៅលើសេវាកម្មឥណទាន និងសេវាប្រាក់បញ្ញើ-សន្សំតែប៉ុណ្ណោះ។ ជាលទ្ធផលប្រតិបត្តិការឥណទានបានផ្លាស់ប្តូរបន្តិចម្តងៗ ពីឥណទានក្រុមក្នុងភូមិទៅជាការកម្ចីជាក្រុម ដែលមានមនុស្សច្រើននាក់ និងកម្ចីឯកត្តជន។ ស្ថាបនាសហគមន៍កម្ពុជា បានធ្វើការផ្លាស់ប្តូរទៅជាស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។ ស្ថាប័នបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៣ ក្រោមឈ្មោះថ្មីថា “ស្ថាបនាសហគ្រិនកម្ពុជា លីមីតធីត”។ នៅក្នុងខែមេសា ឆ្នាំ២០០៣ ស្ថាប័នបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។ ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជាស្ថាបនា លីមីតធីត (SPN) ដែលមានរូបរាជសីហ៍ជាស្តេចសត្វចតុបាទជានិមិត្តសញ្ញានៅក្នុងឆ្នាំ២០០៨។ ស្ថាបនា លីមីតធីត ជាស្ថាប័នទីមួយដែលបានទទួលអាជ្ញាប័ណ្ណកេណ្ឌប្រមូលប្រាក់បញ្ញើ-សន្សំ ពីធនាគារជាតិនៃកម្ពុជានៅក្នុងខែមករា ឆ្នាំ២០០៩។ ស្ថាបនា លីមីតធីតកំពុងផ្តល់ផលិតផលប្រាក់បញ្ញើ ឥណទានខ្នាតតូច និងមធ្យម សេវាផ្ទេរប្រាក់ក្នុងស្រុក និងម៉ាស៊ីនអេធីអឹម។

## សន្ទស្សន៍ប្រតិបត្តិការឆ្នាំ ២០១១-២០១៥

ក្នុងអំឡុងពេលប្រតិបត្តិការប្រាំឆ្នាំចុងក្រោយ ស្ថាបនាទទួលបានភាពរីកចំរើនយ៉ាងខ្លាំងក្នុងអាជីវកម្មរបស់ខ្លួន។ ភាពរីកលូតលាស់ទៅមុខមិនឈប់ឈរនេះបង្កើនគុណភាពប្រតិបត្តិការធនធានមនុស្ស តំបន់ប្រតិបត្តិការ និងដើមទុនបង្វិល។ ដើម្បីគ្រប់គ្រងភាពរីកចំរើនទាំងនេះប្រកបដោយប្រសិទ្ធភាព ស្ថាបនាបានបន្តពង្រឹង និងពង្រីករចនាសម្ព័ន្ធរបស់ខ្លួន ទាំងផ្នែកព័ត៌មានវិទ្យា ប្រតិបត្តិការហិរញ្ញវត្ថុ ប្រព័ន្ធរដ្ឋបាល ការអប់រំផ្ទៃក្នុង និងក្រៅស្ថាប័ន តំបន់ប្រតិបត្តិការ ម៉ាស៊ីនអេធីអឹម គុណភាពឥណទាន អោយមានប្រសិទ្ធភាពខ្ពស់។ ក្រុមហ៊ុនបានពង្រីកតំបន់ប្រតិបត្តិការពី៧៣ការិយាល័យក្នុងឆ្នាំ ២០១១ រហូតដល់ ១៤៩ការិយាល័យក្នុងឆ្នាំ២០១៥ គ្របដណ្តប់លើ២៥ រាជធានី ខេត្ត ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបុគ្គលិកបំរើការងារពេញម៉ោងសរុបចំនួន៣.១២៣នាក់។ ផលបត្រឥណទានបានកើនឡើងយ៉ាងលឿនពី ៩៤,៧ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១១ រហូតដល់ ៤៧២ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ជាមួយនឹងអតិថិជនឥណទានកើនឡើងពី ៥៧.០០១នាក់ រហូតដល់១១២.៦៨៤នាក់ និងរក្សាបាន នូវការសងត្រឡប់ទាន់ពេលជាមធ្យមក្នុងចំនួន ៩៩,៨៤%។ ហានិភ័យឥណទានច្រើនជាង៣០ថ្ងៃ (PAR >30) បាន កើនឡើងបន្តិចពី 0,១៥% ក្នុងឆ្នាំ២០១៤ មក 0,១៦% ក្នុងឆ្នាំ២០១៥ ដែលអាចចាត់ទុកថាជាគុណភាពផលបត្រឥណទានដ៏ល្អប្រសើរបំផុតមួយក្នុងចំណោមមីក្រូហិរញ្ញវត្ថុលើពិភពលោក។ ម្យ៉ាងវិញទៀត ប្រាក់បញ្ញើ-សន្សំរួមមាន គណនីបញ្ញើសំចៃ និងគណនីមានកាលកំណត់ទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋបន្ទាប់ពីស្ថាបនា លីមីតធីត បានដាក់អោយប្រើប្រាស់នូវម៉ាស៊ីន អេធីអឹម (ATM) សរុបចំនួន ៦២ គ្រឿងនាដើមឆ្នាំ ២០១៥។ សមតុល្យប្រាក់បញ្ញើ-សន្សំបានកើនឡើងយ៉ាងគំហុកពី ៣៨,៨លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១១ រហូតដល់ ២៥៩,៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៥ ជាមួយនឹងអតិថិជនកើនឡើងពី ៣៩.៦៦០នាក់ មក១២៧.៩០០នាក់។ ស្ថាបនា អាចរក្សាកេរ្តិ៍ឈ្មោះបានយ៉ាងល្អ និងបានរក្សាដំណែងជាគ្រឹះស្ថានលំដាប់ទីពីរក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុ។ ការចូលរួមរបស់ក្រុមហ៊ុនក្នុងការកាត់បន្ថយភាពក្រីក្រ ការគាំពារបរិស្ថាន និងការចូលរួមទទួលខុសត្រូវក្នុងកិច្ចការសង្គម ត្រូវបានទទួលស្គាល់ទាំងក្នុងប្រទេស និងក្រៅប្រទេស។ ស្ថាបនា លីមីតធីត ក៏មានគំរោងធ្វើការរួមបញ្ចូលគ្នាជាមួយធនាគារពាណិជ្ជដ៏ធំមួយក្នុងឆ្នាំ ២០១៦ ដើម្បីបង្កើនសក្តានុពលភាពក្នុងការផ្តល់សេវាកម្មកាន់តែមានភាពប្រកួតប្រជែង និងងាយស្រួលសំរាប់គ្រួសារកម្ពុជា និងជួយបង្កើនជីវភាពពួកគេអោយរួចផុតពីភាពក្រីក្របានដោយជោគជ័យ។

# ប្រវត្តិសង្ខេប

## ចំណុចសំខាន់នៃការវិវត្តន៍ :

**២០១៥** ក្រោមការគាំទ្រពីសំណាក់ម្ចាស់ភាគទុនិកដ៏រឹងមាំឈ្មោះ MARUHAN Japan Group បានធ្វើអោយស្ថាបនាទទួលបានជោគជ័យកាន់តែប្រសើរឡើងក្នុងឆ្នាំ២០១៥។ ក្រុមហ៊ុន បានពង្រីកតំបន់ប្រតិបត្តិការចំនួន២៣បន្ថែមដែលធ្វើអោយការិយាល័យសរុបកើនឡើងរហូតដល់១៤៩កន្លែង។ លើសពីនេះក្នុងឆ្នាំ ២០១៥ ក្រុមហ៊ុនបានជ្រើសរើសបុគ្គលិកថ្មីបន្ថែមចំនួន ៧៨៤ ដែលធ្វើអោយចំនួនបុគ្គលិកសរុបបានកើនឡើងដល់ ៣.១២៣ នាក់។ ម្យ៉ាងវិញទៀតវគ្គបណ្តុះបណ្តាលចំនួន ១៣៤ ត្រូវបានបង្កើតឡើង និងផ្តល់ដល់បុគ្គលិកចាស់ និងបុគ្គលិកថ្មីៗ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលការងារ គាំទ្រដល់ការរីកចំរើនយ៉ាងលឿនរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនបានដាក់អោយដំណើរការនូវម៉ាស៊ីន ATM សរុបចំនួន៦២គ្រឿង បន្ថែមទៀតដើម្បីបង្កើនភាពងាយស្រួលជូនអតិថិជនរបស់ខ្លួន។ ស្ថាបនា អាចរក្សាគុណភាពឥណទាននិងប្រតិបត្តិការរបស់ខ្លួនបានយ៉ាងល្អ ដោយហានិភ័យឥណទានច្រើនជាង៣០ថ្ងៃ (PAR>30) មានចំនួនត្រឹមតែ ០,១៦% គិតត្រឹមខែធ្នូ ឆ្នាំ២០១៥។ ក្រុមហ៊ុនបន្តនាំមុខក្នុងចំណាត់ថ្នាក់លេខ២ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ សមតុល្យឥណទានសរុបបានកើនដល់ជាង ៤៧២លានដុល្លារ និងមានអតិថិជនប្រាក់កម្ចីសរុបចំនួន ១២២.៦៨៤នាក់។ ស្របពេលជាមួយគ្នានេះសមតុល្យប្រាក់បញ្ញើ-សន្សំ ក៏មានសន្ទុះគួរអោយកត់សំគាល់ ដោយបានកើនឡើងរហូតដល់ជាង២៥៩លានដុល្លារ និងមានកំណើនអតិថិជនប្រាក់បញ្ញើ-សន្សំសរុបចំនួន ១២៧.៩០០នាក់។ កំណើនដ៏គួរអោយកត់សំគាល់នេះបានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន និងជោគជ័យរបស់អតិថិជនក្នុងដំណើរការអាជីវកម្ម ជាពិសេសកំណើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកកាន់ក្រុមហ៊ុន ស្ថាបនា កាន់តែច្រើនឡើងជាលំដាប់។ ជោគជ័យដែលគួរអោយកត់សំគាល់ក្នុងឆ្នាំ២០១៥ គឺជាការរួមបញ្ចូលគ្នារវាង ស្ថាបនា លីមីតធីត ជាមួយធនាគារម៉ារ៉ូហាន់ ជប៉ុន ដែលជាធនាគារពាណិជ្ជដ៏ធំមួយក្នុងប្រទេសកម្ពុជា ដែលបានធ្វើអោយស្ថាបនា កាន់តែមានសក្តានុពលកាន់តែខ្លាំងឡើង។ កំណើននៃការគាំទ្រពីដៃគូរាជរដ្ឋាភិបាល ភាគទុនិក ជាពិសេសអតិថិជន ក៏ជំរុញធ្វើអោយស្ថាបនា គ្រោងនឹងកំលាយខ្លួនទៅជាធនាគារពាណិជ្ជក្នុងឆ្នាំ ២០១៦ខាងមុខ ដើម្បីផ្តល់សេវាកម្មអោយកាន់តែសំបូរបែបនិងអាចបំពេញនូវរាល់តំរូវការផលិតផលធនាគារពាណិជ្ជរបស់អតិថិជន ជួយជំរុញអោយអាជីវកម្មនិងសេដ្ឋកិច្ចគ្រួសារអោយរឹតតែប្រសើរឡើង។

**២០១៤** ស្ថាបនា លីមីតធីត បន្តទទួលបានជោគជ័យគួរអោយកត់សំគាល់ក្នុងឆ្នាំ ២០១៤ បន្ទាប់ពីគ្រឹះស្ថានបានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនទូទាំង ២៥ រាជធានីខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនបានបើកអោយដំណើរការនូវសាខាថ្មីចំនួន៦ និងប៉ុស្តិ៍សេវា ចំនួន ៩ បន្ថែមដែលធ្វើអោយការិយាល័យសរុបបានកើនឡើងដល់ ១២៦។ ម៉ាស៊ីន ATM ត្រូវបានដាក់អោយដំណើរការដោយជោគជ័យ និងទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំងពីសំណាក់អតិថិជន។ និន្នាការរបស់គ្រឹះស្ថានក្នុងការផ្តល់ផលិតផលមីក្រូហិរញ្ញវត្ថុមានលក្ខណៈប្រកួតប្រជែងប្រកបដោយសុវត្ថិភាពខ្ពស់ និងការប្តេជ្ញាចិត្តរបស់បុគ្គលិកក្នុងការផ្តល់សេវាកម្មប្រកបដោយវិជ្ជាជីវៈការងារជូនដល់អតិថិជនធ្វើអោយស្ថាបនា ក្លាយជាជំរើសទីមួយក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុកម្ពុជា។ ជាលទ្ធផល ស្ថាបនា លីមីតធីតបានទទួលពានរង្វាន់ The Outstanding Retail MFI ពីក្រុមទិន្នន័យអន្តរជាតិ (IDG) និងគ្រឿងឥស្សរិយយសពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០១៤។ គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ សមតុល្យឥណទានសរុបបានកើនដល់ជាង ៣១១ លានដុល្លារអាមេរិក និងមានអតិថិជនប្រាក់កម្ចីសរុបចំនួន ៩៤.៨៥២ នាក់។ ស្របពេលជាមួយគ្នានេះសមតុល្យប្រាក់បញ្ញើ-សន្សំបានកើនឡើងយ៉ាងគំហុករហូតដល់ជាង ១៦៦លានដុល្លារអាមេរិក ដែលមានអតិថិជនប្រាក់បញ្ញើ-សន្សំសរុបចំនួន ៨៧.១៧៩នាក់។ កំណើននេះបាននាំអោយ ស្ថាបនា លីមីតធីតឈានជើងពីចំណាត់ថ្នាក់លេខ៣ឡើងមកលំដាប់ថ្នាក់លេខ២ក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុ។ កំណើនភាពជឿជាក់របស់អតិថិជន និងការគាំទ្រយ៉ាងពេញទំហឹងពីដៃគូភាគទុនិករបស់ខ្លួន ធ្វើអោយ

# ប្រវត្តិសង្ខេប

ស្ថាបនាមើលឃើញឱកាសជោគជ័យរបស់ខ្លួនបន្ថែមទៀតក្នុងទីផ្សារមីក្រូហិរញ្ញវត្ថុកម្ពុជានាឆ្នាំ ២០១៥ ខាងមុខនេះ។

**២០១៣** នេះជាឆ្នាំដ៏ល្អសំរាប់អាជីវកម្មនានា រួមទាំងសំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីតផងដែរ។ ក្រុមហ៊ុនទទួលបានភាពរីកចំរើនយ៉ាងខ្លាំងបើទោះជាមានវិបត្តិនយោបាយបណ្តាលមកពីការមិនទទួលយកលទ្ធផលបោះឆ្នោតនាថ្ងៃទី២៨ ខែកក្កដា យ៉ាងណាក៏ដោយប៉ុន្តែការត្រឡប់មកវិញយ៉ាងឆាប់រហ័សនៃស្ថេរភាពសង្គម បានបង្កអោយមានឱកាសអាជីវកម្មជាច្រើនសំរាប់សហគ្រិនកម្ពុជាក្នុងការពង្រីកមុខជំនួញរបស់ពួកគេអោយទទួលបានជោគជ័យ។ ស្ថាបនា លីមីតធីតសម្រេចបានជោគជ័យយ៉ាងខ្លាំងក្នុងឆ្នាំនេះ ដោយក្រុមហ៊ុនសម្រេចបានបេសកកម្មរបស់ខ្លួនក្នុងការពង្រីកសេវាកម្មមីក្រូហិរញ្ញវត្ថុអោយបានដល់គ្រប់ ២៥ ខេត្ត រាជធានី នៅទូទាំងព្រះរាជាណាចក្រកម្ពុជាតាមរយៈការិយាល័យប្រតិបត្តិការរបស់ខ្លួនសរុបចំនួន ១១១ និងបុគ្គលិកសរុប ចំនួន ២.១៤៧នាក់។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៣ ផលប័ត្រឥណទានបានកើនឡើងចំនួន ៥០% និងអាចរក្សាគុណភាពផលប័ត្រឥណទានបានយ៉ាងល្អប្រសើរ ដោយអត្រាហានិភ័យឥណទានច្រើនជាង ៣០ថ្ងៃ មានត្រឹមតែ ០,២% ប៉ុណ្ណោះ។ គិតត្រឹមចុងខែធ្នូ ឆ្នាំ ២០១៣ ផលប័ត្រឥណទានសរុបមានចំនួន ១៨១,៥ លានដុល្លារសហរដ្ឋអាមេរិក និង មានអតិថិជនប្រាក់កម្ចីសរុបចំនួន ៧៨.៨៦២នាក់។ សេវាកម្មប្រាក់បញ្ញើ-សន្សំ ដែលជាផលិតផលថ្មីរបស់ក្រុមហ៊ុនបានទទួលការពេញនិយមយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋ ដោយទឹកប្រាក់បានកើនឡើងពី ៦៦ លានដុល្លារសហរដ្ឋអាមេរិក ក្នុងខែធ្នូ ឆ្នាំ ២០១២ មក ៨០,៥លាន ដុល្លារសហរដ្ឋអាមេរិក គិតត្រឹមខែធ្នូ ឆ្នាំ២០១៣ ដែល ធ្វើអោយស្ថាបនា លីមីតធីតក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុលំដាប់ថ្នាក់លេខមួយក្នុងទីផ្សារហិរញ្ញវត្ថុលើការប្រមូលប្រាក់បញ្ញើ-សន្សំ។ សមិទ្ធផលនេះបានឆ្លុះបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់ក្នុងការចាត់ចែងប្រតិបត្តិការរបស់ខ្លួនដើម្បីទទួលបានការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ និងអាចបង្កើនកិត្យានុភាពរបស់ក្រុមហ៊ុនអោយបានលេចធ្លោឡើង។ ស្ថាបនា គ្រោងនឹងដាក់អោយដំណើរការម៉ាស៊ីន ATM របស់ក្រុមហ៊ុននាឆ្នាំ ២០១៤ ផងដែរ។

**២០១២** ស្ថាបនា លីមីតធីត នៅតែអាចបន្តកំណត់ត្រាជោគជ័យថ្មីក្នុងទំព័រប្រវត្តិសាស្ត្ររបស់ខ្លួន ខណៈពេលដែលក្នុងកំឡុងឆ្នាំនេះ ក្រុមហ៊ុនបានព្យាយាមស្វែងរកដៃគូភាគទុនិកសមរម្យ ដែលអាចគាំទ្របេសកកម្ម និងទស្សនៈវិស័យរបស់ខ្លួនបាន ហើយជាលទ្ធផលក្រុមហ៊ុន Maruhan Japan Bank ដែលជាក្រុមហ៊ុនពាណិជ្ជក្នុងប្រទេសកម្ពុជាបានក្លាយជាដៃគូភាគទុនិកសំខាន់របស់ស្ថាបនា។ គិតមកត្រឹមខែធ្នូ ឆ្នាំ២០១២ ក្រុមហ៊ុនស្ថាបនា លីមីតធីតបានធ្វើប្រតិបត្តិការរបស់ខ្លួននៅការិយាល័យសរុប ៨៨ (សាខាចំនួន ៦៥ ប៉ុស្តិ៍សេវា ២៣) ដែលមានទីតាំងនៅ ២២ ខេត្ត/ ក្រុង ក្នុងចំណោមខេត្តទាំង ២៤។ ក្រុមហ៊ុនបានផ្តល់ប្រាក់កម្ចីអោយអតិថិជនសរុបចំនួន ៦៨.១៩៥ នាក់ ហើយផលប័ត្រឥណទានរបស់ខ្លួនមានចំនួន ១២១ លានដុល្លារសហរដ្ឋអាមេរិក ដែលជាចំនួនកើនឡើងច្រើនជាងឆ្នាំ ២០១១ ប្រមាណ ២៩%។ ការប្រមូលប្រាក់បញ្ញើ-សន្សំពីប្រជាពលរដ្ឋទូទៅប្រមាណ ៤៧.៦៧៦ នាក់ បានកើនឡើងច្រើនជាងមុន ៧២% ដែលមានទឹកប្រាក់សន្សំសរុបរហូតដល់ ៦៦,៧ លានដុល្លារសហរដ្ឋអាមេរិក។ ចំនួនបុគ្គលិកបានកើនឡើងច្រើនជាងមុន ២៨% ស្មើនឹង ១.៧១០ នាក់។ ជោគជ័យដែលគួរអោយកត់សំគាល់ជាងគេ គឺការគ្រប់គ្រងគុណភាពផលប័ត្រឥណទានដែលក្រុមហ៊ុនអាចរក្សាហានិភ័យឥណទានបង់យឺតជាង៣០ថ្ងៃ (PAR>៣០ ថ្ងៃ) នៅ ០,៣៩% ដែលវាបានបង្ហាញអំពីប្រសិទ្ធភាព ការគ្រប់គ្រងគុណភាពឥណទានបានយ៉ាងល្អ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនបានជំនះការងារដ៏លំបាកក្នុងការសម្រេចដាក់អោយប្រើប្រាស់ប្រព័ន្ធធនាគារផ្ទៃក្នុងថ្មីមានឈ្មោះថា Oracle Financial System Flexcube។

**២០១១** នេះជាឆ្នាំដ៏ជោគជ័យមួយទៀត។ ស្ថាបនា លីមីតធីត បានបន្តប្រតិបត្តិការរបស់ខ្លួនប្រកបដោយភាពជោគជ័យ និងបានបង្កើតកំណត់ត្រាជាច្រើនដោយបានពង្រីកតំបន់ប្រតិបត្តិការលើតំបន់ជាច្រើន ដើម្បីបម្រើដល់

# ប្រវត្តិសង្ខេប

ប្រជាជនក្នុងប្រទេស។ ក្រុមហ៊ុនបានបង្កើនផលប័ត្រឥណទាន និងការប្រមូលប្រាក់បញ្ញើ-សន្សំ ព្រមទាំងរក្សាបាននូវគុណភាពឥណទានក្នុងកម្រិតដ៏ល្អ។ គិតត្រឹមចុងខែធ្នូ ឆ្នាំ២០១១ ស្ថាបនា លីមីតធីត បានធ្វើប្រតិបត្តិការលើការិយាល័យចំនួន ៧៣(សាខា ៥៣ និងប៉ុស្តិ៍សេវា២០) គ្របដណ្តប់លើ ១៧ ខេត្ត/ក្រុង និងបានផ្តល់ប្រាក់កម្ចីជូនដល់អតិថិជនចំនួន ៥៧.០០១នាក់ ដែលមានទឹកប្រាក់ស្មើនឹង ៩៤,៧ លាន ដុល្លារអាមេរិក កើនឡើង ៦៤% បើប្រៀបនឹងឆ្នាំមុន និងបានប្រមូលប្រាក់បញ្ញើ-សន្សំពីអតិថិជនចំនួន ៣៩.៦៦០នាក់ ដែលមានទឹកប្រាក់ចំនួន ៣៨,៨ លាន ដុល្លារអាមេរិក មានការកើនឡើង ១២៩%។ ខណៈពេលនេះដែរក្រុមហ៊ុនអាចរក្សាបាននូវហានិភ័យឥណទានទាបជាងមួយថ្ងៃនៅត្រឹមកម្រិត ០,២២%។ ចំនួនបុគ្គលិកមានការកើនឡើងដល់ ១.៣៣៩ នាក់។ ស្ថាបនាទទួលបានពានរង្វាន់សុវត្ថិភាពបច្ចេកវិទ្យាជាន់ខ្ពស់ (CSO) ពីសមាគមប្រជាជាតិអាស៊ានក្នុង ខែធ្នូ ឆ្នាំ២០១១។ បន្ថែមពីនេះទៀត ស្ថាបនាបានបង្កើនដើមទុនរហូតដល់ ២០០% ក្នុងឆ្នាំនេះ និងបានសម្រេចអនុម័តអោយប្រើប្រាស់ប្រព័ន្ធធនាគារថ្មី Oracle Financial System, Flexcube ដើម្បីគាំទ្រដល់ការរីកចម្រើនរបស់ក្រុមហ៊ុន។

**២០១០** ជាពេលដែលវិបត្តិហិរញ្ញវត្ថុបានកន្លងផុតទៅ ប៉ុន្តែបានបន្សល់ទុកនូវផលប៉ះពាល់ដល់សេដ្ឋកិច្ចក្នុងប្រទេស។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថាបនា លីមីតធីត នៅតែបានបង្កើតកំនត់ត្រាជោគជ័យដ៏ល្អក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយបានសម្រេចកំណើនផលប័ត្រឥណទានរហូតដល់៤៦% កើនពី ៣៩,៦៩ លានដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០៩ ដល់ ៧,៧៧ លានដុល្លារសហរដ្ឋអាមេរិកគិតត្រឹមខែធ្នូ ឆ្នាំ២០១០។ ក្នុងនោះសម្រេចបានការកាត់បន្ថយហានិភ័យផលប័ត្រឥណទានក្រោយពេល ៣០ ថ្ងៃពី ២,១៣% នៅឆ្នាំ ២០០៩ មកត្រឹម ០,៩៣% នៅឆ្នាំ ២០១០។ ស្ថាប័ន បានសម្រេចជោគជ័យក្នុងការប្រមូលប្រាក់បញ្ញើ-សន្សំសាធារណៈកើនឡើងដល់ ៤៥៦% ដោយគិតជាសាច់ប្រាក់មានការកើនឡើងពី ៣ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០០៩ ដល់ ១៧ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១០ ធ្វើអោយស្ថាបនា ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាំមុខគេក្នុងការប្រមូលប្រាក់បញ្ញើ-សន្សំ។ ក្នុងកំឡុងឆ្នាំនេះដែរ ស្ថាបនាបានអញ្ជើញក្រុមប្រឹក្សាភិបាលឯករាជ្យពីររូបបន្ថែមទៀត ដែលមានជំនាញក្នុងវិស័យកសិកម្ម និងគ្រប់គ្រងអាជីវកម្ម ដើម្បីបំពេញជំនាញចម្រុះក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចតាមលក្ខខណ្ឌជានិយ័តករ។ ផែនការរយៈពេលប្រាំឆ្នាំ ២០១១-២០១៥ ត្រូវបានបង្កើត និងទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុនដែលផ្តល់នូវ ទិសដៅយ៉ាងច្បាស់លាស់សម្រាប់ការគ្រប់គ្រងនាពេលអនាគត។ បន្ថែមពីនេះទៀត FLEXCUBE ដែលជាដំណោះស្រាយធនាគារថ្មីត្រូវបានអនុម័ត និងចាប់ផ្តើមអនុវត្តដើម្បីផ្តល់នូវសក្តានុពលថ្មីដល់គ្រឹះស្ថាន ក្នុងឆ្នាំខាងមុខ។

**២០០៩** ស្ថាបនា លីមីតធីត បានទទួលអាជ្ញាប័ណ្ណកេណ្ឌប្រមូលប្រាក់បញ្ញើ-សន្សំពី ធនាគារជាតិនៃកម្ពុជានៅក្នុងខែមករា ដែលធ្វើអោយស្ថាបនាក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទីមួយក្នុងការទទួលបាននូវអាជ្ញាប័ណ្ណនេះ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏មានការផ្តល់សេវាទូទាត់តាមរយៈអន្តរសាខាផងដែរ ដើម្បីជួយសម្រួលក្នុងការកេណ្ឌប្រមូលប្រាក់បញ្ញើ-សន្សំ។ អាជ្ញាប័ណ្ណនេះបានជួយជំរុញឱ្យស្ថាបនា លីមីតធីត កាន់តែទទួលបានផលប្រយោជន៍បន្ថែមក្នុងការទាក់ទាញការប្រមូលប្រាក់បញ្ញើ-សន្សំប្រកបដោយជោគជ័យ។ នៅចុងឆ្នាំ ២០០៩ តួលេខនៃប្រាក់បញ្ញើ-សន្សំស្ថិតនៅលំដាប់លើគេក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃ។ ស្ថាបនា មានផលប័ត្រឥណទានចំនួន ៣៩,៧លានដុល្លារអាមេរិក អតិថិជនមានចំនួន៣៦.២២៨នាក់ និងបានបង្កើតសាខាស្រុកថ្មីចំនួន ១ ដែលសរុបសាខាទាំងអស់មានចំនួន ៣៤សាខា និងមានបុគ្គលិក ចំនួន ៧៤៧ នាក់។ ក្នុងខែមេសា ShoreCap International បានសំរេចចិត្តចាកចេញ និងផ្ទេរភាគហ៊ុនរបស់ខ្លួនទៅអោយម្ចាស់ភាគហ៊ុនថ្មីគឺ Developing World Market (DWM)។ នេះជាឆ្នាំដែលអាជីវកម្មភាគច្រើនត្រូវបានទទួលរងផលប៉ះពាល់ដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោក និងបានប៉ះពាល់ដល់វិស័យមីក្រូហិរញ្ញ វត្ថុនានារួមទាំង ស្ថាបនា លីមីតធីត

# ប្រវត្តិសង្ខេប

ក៏បានទទួលរងផលប៉ះពាល់នេះដែរ។ ថ្នាក់គ្រប់គ្រង និងបុគ្គលិកបានខិតខំប្រឹងប្រែងជំនះរាល់ការលំបាកក្នុងការធ្វើអោយប្រតិបត្តិការប្រព្រឹត្តទៅដោយភាពរលូន។ ជាលទ្ធផល ស្ថាបនា លីមីតធីត អាចគ្រប់គ្រងការរីកចំរើននៃផលប័ត្រឥណទានរហូតដល់ ៦% ដោយរក្សាបាននូវគុណភាពឥណទាន (PAR) ច្រើនជាង ៣០ថ្ងៃស្មើ ២% ខណៈពេលដែលប្រាក់ចំណេញទាបជាងផែនការ ១០%។ ទោះបីជាយ៉ាងនេះក្តី នេះជាស្នាដៃដ៏ល្អប្រសើរបំផុតក្នុងចំណោមស្ថាប័នដទៃ។

**២០០៨** វិស័យមីក្រូហិរញ្ញវត្ថុមានការរីកចំរើនយ៉ាងលឿនដែលធ្វើឱ្យការប្រកួតប្រជែងមានការកើនឡើងជាខ្លាំងក្នុងចំណោមប្រតិបត្តិករ។ ថ្នាក់គ្រប់គ្រង និងបុគ្គលិកបានផ្តោតទៅលើការកែច្នៃ និងអភិវឌ្ឍផលិតផលសេវាកម្ម ក៏ដូចជាពង្រឹងសមត្ថភាពរបស់ថ្នាក់គ្រប់គ្រងដើម្បីជានាភាពជោគជ័យយូរអង្វែង និងនិរន្តរភាព។ ក្រុមហ៊ុនបានសំរេចចិត្តប្តូរឈ្មោះទៅជា ស្ថាបនា លីមីតធីត ដោយមានរូបសញ្ញារាជសីហ៍ជានិមិត្តសញ្ញា។ ការិយាល័យគ្រប់សាខាទាំងអស់ត្រូវបានរៀបចំកែលំអដើម្បីកសាងទំនុកចិត្តនៅក្នុងសហគមន៍។ ក្រុមហ៊ុនបានបង្កើតសាខាខេត្តចំនួន ៣ និង សាខាស្រុក ១ ដែលសរុបទាំងអស់មានចំនួន ៣៣ សាខា បុគ្គលិកមានចំនួន ៦៥៣នាក់ អតិថិជនចំនួន ៣៧.១៥៩នាក់ (មានកំណើន ៥៥%) ផលប័ត្រឥណទាន ៣៧.៥ លានដុល្លារអាមេរិក (មានកំណើន៦៧%) និងអាចរក្សាអត្រាសងទាន់ពេលបាន ៩៩,៩១% និង អត្រាទទួលបានមកវិញពីទ្រព្យម្ចាស់ ៣៨,៤៨%។

**២០០៧** ជាឆ្នាំដ៏សំខាន់សំរាប់ CEB ដោយសម្រេចបានសមិទ្ធិផលជាច្រើននៅក្នុងឆ្នាំដែលជាលទ្ធផលទទួលបានពីការព្យាយាមក្នុងឆ្នាំ ២០០៦ ដូចជាប្រព័ន្ធគណនេយ្យ MB-Win នាយកដ្ឋាននីមួយៗមានដំណើរការបានល្អដោយរាប់បញ្ចូលផ្នែកប្រតិបត្តិការហិរញ្ញវត្ថុ រដ្ឋបាល ព័ត៌មានវិទ្យា ធនធានមនុស្ស ទីផ្សារ និងសវនកម្មផ្ទៃក្នុង។ ទាំងនេះជំរុញឱ្យ CEB គ្រប់គ្រង អាជីវកម្មបានល្អ។

ឆ្នាំនេះសាខាខេត្តចំនួន ៦ និង សាខាស្រុកចំនួន ២ ត្រូវបានបង្កើតឡើង ដែលនាំឱ្យសាខាប្រតិបត្តិការមានចំនួនសរុប ២៨ និងអាចរួចថ្លៃ ដើមក្នុងរយៈពេល ៦ខែ ក្រោយពីចាប់ផ្តើមប្រតិបត្តិការ។ កំណើនផលប័ត្រឥណទានមានចំនួន ៨៧% ដោយរក្សាអត្រាសងទាន់ពេលបាន ៩៩,៩៤% និងការទទួលបានមកវិញពីទ្រព្យម្ចាស់ (Return on Equity) ក្នុងអត្រា ៣១,០៦%។ ផលប័ត្រឥណទាននៅចុងឆ្នាំមានចំនួន ២២,៤លានដុល្លាអាមេរិក អតិថិជនចំនួន ២៦.០៤៨ នាក់ និងបុគ្គលិកចំនួន ៤៦៥ នាក់។ CEB មានផែនការទៅមុខជានិច្ច ដើម្បីរក្សាខ្លួនធ្វើជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនាំមុខគេសំរាប់រយៈពេលយូរអង្វែង។ ក្រុមប្រឹក្សាភិបាលបានឯកភាពលើការផ្លាស់ប្តូរទីតាំងថ្មីរបស់ការិយាល័យកណ្តាលនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស ដែលមានទីកន្លែងធំទូលាយក្នុងការគាំទ្រការលូតលាស់របស់ក្រុមហ៊ុន។ CEB ទទួលបានជោគជ័យក្នុងការសាកល្បងលើផ្តល់សេវាកម្មកេណ្ឌប្រមូលប្រាក់បញ្ញើ-សន្សំ និងប្តេជ្ញាចិត្តដើម្បីទទួលអាជ្ញាប័ណ្ណកេណ្ឌប្រមូលប្រាក់បញ្ញើ-សន្សំសាធារណៈនៅឆ្នាំខាងមុខ។

**២០០៦** អ្នកវិនិយោគល្បីឈ្មោះចំនួន ២ មកពីប្រទេសហូឡង់គឺ FMO និង Triodos មានចំណាប់អារម្មណ៍លើស្ថានភាពទ្រព្យម្ចាស់របស់ CEB ហើយម្នាក់ៗបានវិនិយោគ ១៨,៤៧% ស្មើៗគ្នានៃដើមទុនចុះបញ្ជីសរុប។ នាឆ្នាំនោះ CEB មានភាគទុនិកចំនួន ៥ ដែលភាគ ទុនិកចំនួន ២ ជាភាគទុនិកក្នុងស្រុក និង ៣ ទៀតជាបរទេស។ ភាគទុនិកថ្មីបាននាំមកនូវដើមទុនបន្ថែមក៏ដូចជាបទពិសោធន៍ និងជំនាញផ្សេងៗសំរាប់ក្រុមប្រឹក្សាភិបាល។ អភិបាល ៥រូបតំណាងឱ្យភាគទុនិករបស់ CEB ដែលក្នុងនោះពីររូបជាអភិបាលឯករាជ្យបានរួមគ្នាបង្កើតជារចនាសម្ព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ។ ប្រព័ន្ធ Micro Banker for Windows (MBWin) ជាប្រព័ន្ធកម្មវិធីគណនេយ្យមួយដែលអាចជួយគាំទ្រការរីកចំ រើនរបស់ CEB បាន។ ប្រព័ន្ធថ្មីនេះបានធ្វើឱ្យ CEB ពង្រីកប្រតិបត្តិការទៅដល់ ៧សាខាថ្មីទៀត ដោយបង្កើនផលប័ត្រឥណទានបាន ៩៦% និង PAR ក្រោយ ៣០ថ្ងៃមានសភាពល្អជាងមុនពី ១% ក្នុងឆ្នាំ ២០០៥

# ប្រវត្តិសង្ខេប

មកនៅត្រឹម ០,២៣% ក្នុងឆ្នាំ ២០០៦។ បន្ថែមពីនេះ CEB ទទួលបានពានរង្វាន់តម្លាភាពហិរញ្ញវត្ថុពី CGAP សំរាប់ប្រតិបត្តិការឆ្នាំនេះ។ ផលប័ត្រឥណទានមានចំនួន ១២,៣ លានដុល្លារអាមេរិក និង មានអតិថិជនចំនួន ១៥.១១២ នាក់ និងបុគ្គលិកពេញម៉ោងចំនួន ២៨០នាក់ ធ្វើប្រតិបត្តិការនៅតាមសាខាចំនួន ២១។

**២០០៥** CEB បានធ្វើប្រតិបត្តិការក្នុង ៥ខេត្ត ដែល មាន ១៤សាខា មានបុគ្គលិកបំរើការ ១៩១ នាក់ និងអតិថិជនសរុប ៨.៨១១នាក់។ ផលប័ត្រឥណទាន នៅខែធ្នូ ឆ្នាំ ២០០៥ មានចំនួន ៦.៣លានដុល្លារអាមេរិក។ ជោគជ័យដ៏គួរឱ្យកត់សំគាល់គឺ CEB អាចគ្រប់គ្រងគុណភាពផលប័ត្រឥណទាននៅក្នុងកំរិតមួយខ្ពស់ដោយរក្សា PAR ធំជាង ៣០ ថ្ងៃនៅអត្រា ១% បានជាច្រើនឆ្នាំ។ CEB បានកំពុងស្វែងរកអ្នកវិនិយោគថ្មីចំនួន២ទៀត ដើម្បីបង្កើនដើមទុន និងគាំទ្រផែនការពង្រីកខ្លួនតទៅទៀត។

**២០០៤** ShoreCap International មានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីលទ្ធផលទទួលបានរបស់ CEB ក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈសេវាកម្មរបស់ CEB។ ពួកគេបានចូលរួមភាគហ៊ុនលើបេសកកម្មដោយវិនិយោគរហូតដល់ ៤៣% នៃចំនួនភាគហ៊ុនសរុបរបស់ CEB។ ម្ចាស់ភាគហ៊ុនថ្មីនៅពេលនោះគឺ ShoreCap International ៤៣%, អង្គការស្ថាបនាសហគមន៍កម្ពុជា ៤៥% និងក្រុមហ៊ុនបុគ្គលិក ១២%។ ភាគហ៊ុនចុះបញ្ជីសរុបមានចំនួន ១.១៥៨.៤៧០ ដុល្លារអាមេរិក។ CEB បានបង្កើនតំបន់ប្រតិបត្តិការសរុបទាំងអស់ចំនួន ១៤ សាខា បុគ្គលិកបំពេញការងារពេញម៉ោងចំនួន ១៣៥ នាក់ បំរើអតិថិជនចំនួន ៥.៧៦០នាក់ ផលប័ត្រឥណទានចំនួន ៣.៧០២.៧៨៣ ដុល្លារអាមេរិក និងរក្សាអត្រាសងទាន់ពេល ៩៩,៣៦% ។

**២០០៣** CEB បានទទួលអាជ្ញាប័ណ្ណពីក្រសួងពាណិជ្ជកម្មជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត និងទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រោមឈ្មោះថ្មី ស្ថាបនាសហគ្រិនកម្ពុជាលីមីតធីត។ អង្គការស្ថាបនាសហគមន៍កម្ពុជា គឺជាម្ចាស់ភាគហ៊ុន ៨១% នៃដើមទុនចុះបញ្ជីសរុប និង SEI (អតីត CEBEC) ជាម្ចាស់ភាគហ៊ុន ១៩%។ ភាគហ៊ុនចុះបញ្ជីសរុបមានចំនួន ៣៧២.០០០ ដុល្លារអាមេរិក។ អាជ្ញាប័ណ្ណបានធ្វើឱ្យ CEB អាចទទួលឥណទានពីប្រទេសអន្តរជាតិផ្សេងៗគ្នា។ BlueOrchard និង Triodos ដែលជាម្ចាស់ភាគហ៊ុនអន្តរជាតិដំបូងបំផុតបានធ្វើការជាមួយ CEB។ តំបន់ប្រតិបត្តិការបានកើនឡើងចំនួន ៥សាខាខេត្ត និង ៣សាខាស្រុក ហើយចំនួនបុគ្គលិកពេញម៉ោងសរុបចំនួន ១១៦នាក់ បំរើអតិថិជនសកម្មចំនួន ៧.០២០នាក់ និងផលប័ត្រឥណទានមានចំនួន ១.៩៣៥.៣៣៧ ដុល្លារអាមេរិក។

**២០០២** គ្រឹះស្ថានបានកំលាយខ្លួន និងចាប់ផ្តើមយុទ្ធសាស្រ្តថ្មីក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់បុគ្គលិកពីការគិតជាលក្ខណៈអង្គការក្រៅរដ្ឋាភិបាលទៅជាការគិតមួយផ្សេងទៀតគឺការរកប្រាក់ចំណេញ។ វគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានផ្តល់ដល់បុគ្គលិកដើម្បីជាជំនួយដល់ការកំលាយខ្លួននេះក្រោមការគាំទ្ររបស់ MPDF និង GTZ។ នៅចុងឆ្នាំ ២០០២ រាល់ឯកសារកំលាយខ្លួនទាំងអស់ត្រូវបានបញ្ចប់ និងបានបញ្ជូនទៅក្រសួងដែលពាក់ព័ន្ធ។ CCB បានបង្កើនតំបន់ប្រតិបត្តិការចំនួន ៣ សាខាខេត្ត និង ៣ សាខាស្រុកទៀត មានផលប័ត្រឥណទានចំនួន ១.៤៣១.២០៥ ដុល្លារអាមេរិក អតិថិជនចំនួន ៥,៩០០នាក់ និងបុគ្គលិកចំនួន ៩៣ នាក់។

**២០០១** អត្រាការប្រាក់ដែលបានគិតពីអតិថិជនមានការធ្លាក់ចុះចំនួន ៥០% ដោយសារការផ្លាស់ប្តូររូបមន្តគណនាទៅជាវិធីសាស្រ្តថយចុះ (Declining Method)។ CCB បានទទួលឥណទានពាណិជ្ជកម្មពីធនាគារអភិវឌ្ឍជនបទ។ CCB បានបង្កើនផលប័ត្រឥណទានទៅដល់ ៨៧៧.៦០៤ ដុល្លារអាមេរិក បំរើអតិថិជនចំនួន ៣.៩៧៥នាក់ និងមានបុគ្គលិកបំរើការពេញម៉ោងចំនួន ៩១ នាក់។

# ប្រវត្តិសង្ខេប

**២000** CCB បានកំលាយខ្លួនដោយជោគជ័យពីអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រកបដោយវិជ្ជាជីវៈ និងឯករាជ្យពីម្ចាស់មូលនិធិ និងម្ចាស់ជំនួយសំរាប់ការចំណាយក្នុងប្រតិបត្តិការដោយមិនចាំបាច់មានប្រភពទុន ដែលបានពីម្ចាស់ជំនួយទៀតឡើយ។ ថ្នាក់គ្រប់គ្រង និងបុគ្គលិកបានដឹកនាំ និងចាត់ចែងប្រតិបត្តិការដោយសំរេចបានជោគជ័យក្នុងការឈានទៅធ្វើហិរញ្ញប្បទានដោយខ្លួនឯងប្រកបដោយនិរន្តរភាព។ CCB មានបុគ្គលិកសរុបចំនួន ៨៣នាក់ ដែលធ្វើប្រតិបត្តិការក្នុងសាខាខេត្តចំនួន ៣ និងសាខាស្រុកចំនួន ១ មានអតិថិជនសរុបចំនួន ៥.៣៥៥ នាក់ និងមានផលប័ត្រឥណទានចំនួន ៥២៥.៧០៤ ដុល្លារអាមេរិក។

**១៩៩៩** បានអនុវត្តវិធីសាស្ត្រមីក្រូហិរញ្ញវត្ថុខ្នាតតូច ដោយផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុរួមមានសេវាឥណទាន និងសេវាបញ្ញើ-សន្សំ។ បានកាត់បន្ថយកម្មវិធីអប់រំផ្នែកសុខភាពរហូតដល់ចុងឆ្នាំ ១៩៩៩ ដែលក្រុមហ៊ុនបានសម្រេចលុបចោលជាស្ថាពរ និងបានផ្តល់ផលិតផលប្រាក់កម្ចីឯកត្តជនជាប្រាក់ដុល្លារ និងសេវាកម្មនៅតាមការិយាល័យសាខា។

**១៩៩៨** សេវាកម្មមីក្រូហិរញ្ញវត្ថុ និងកម្មវិធីអប់រំសុខភាពក្នុងលក្ខណៈជាធនាគារសហគមន៍ ត្រូវបានផ្តល់ជូនស្ត្រីនៅក្នុងសហគមន៍។ ផលិតផល និងសេវាកម្ម ផ្សេងៗពីគ្នាត្រូវបានបង្កើតឡើង និងផ្តល់ជូនទៅអតិថិជនចាប់ពីពាក់កណ្តាលឆ្នាំរួមមាន៖ ឥណទានជាក្រុម ឥណទានឯកត្តជន ឥណទានជាប្រាក់ដុល្លារ និងសេវាកម្មផ្សេងៗទៀតនៅតាមសាខា និងអនុសាខារបស់ខ្លួន។

**១៩៩៥** អង្គការស្ថាបនា សហគមន៍កម្ពុជា ត្រូវបានបង្កើត និងចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ជាអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ និងទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការនៅក្នុងខែសីហា ឆ្នាំ១៩៩៦។ CCB បានផ្តល់សេវាកម្មហិរញ្ញវត្ថុ និងកម្មវិធីអប់រំសុខភាពដល់សហគមន៍ក្រីក្រ។

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល



ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលរបស់ស្ថាបនា លីមីតធីត និងជាអ្នកតំណាងភាគទុនិក MARUHAN Japan Bank Plc. ខ្ញុំពេញចិត្តក្នុងការបង្ហាញអំពីជោគជ័យដ៏ល្អប្រសើរដែល ស្ថាបនា លីមីតធីត សម្រេចបានក្នុងឆ្នាំ ២០១៥ កន្លងទៅ។ ខ្ញុំសូមធ្វើការថ្លែងអំណរគុណចំពោះការតាំងចិត្តដ៏មុតមាំរបស់ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ក្នុងការជំនះរាល់ឧបសគ្គស្របពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាបន្តរីកលូតលាស់ទៅមុខ។

ក្នុងឆ្នាំ ២០១៥ ផលិតផលជាតិប្រមាណប្រចាំឆ្នាំរបស់ប្រទេសកម្ពុជាបានកើនឡើង ៦,៩% ដែលជាកំណត់ត្រានៃការធ្លាក់ចុះបន្តិច បើប្រៀបធៀបជាមួយកំណត់ត្រា ៧,២% កាលពីឆ្នាំ ២០១៤។ ជោគជ័យដ៏ល្អនេះបណ្តាលមកពីការបន្តនាំចេញផលិតផលសំលៀកបំពាក់ជាច្រើន កំណើនឡើងនៃវិស័យសេវាកម្មដែលភាគច្រើនជាវិស័យទេសចរណ៍ និងសកម្មភាពអចលនទ្រព្យនានាដែលរួមផ្សំដោយភាពរីកចំរើនដ៏ខ្លាំងក្លានៃវិស័យហិរញ្ញវត្ថុ និងការអនុវត្តផ្នែកវិស័យកសិកម្មល្អជាងមុន។

ផលប័ត្រឥណទានរបស់ស្ថាបនា លីមីតធីត កើនឡើង៥២% ដែលមានចំនួនទឹកប្រាក់ជាង ៤៧២លានដុល្លារសហរដ្ឋអាមេរិក ខណៈពេលដែលក្រុមហ៊ុនបានបន្តរក្សាគុណភាពផលប័ត្រឥណទាននៅខ្ពស់ដដែល។ កំណើនប្រាក់បញ្ញើសន្សំមានចំនួនគួរអោយកត់សំគាល់គឺ ៥៦% ស្មើនឹង ២៦០លានដុល្លារសហរដ្ឋអាមេរិក ដែលជាទឹកប្រាក់អាចផ្គត់ផ្គង់ក្នុងសកម្មភាពតំរូវការសាច់ប្រាក់នានារបស់អតិថិជនរបស់ខ្លួន។ ប្រាក់ចំណេញសុទ្ធកើនឡើង ៨០% ស្មើនឹង ១៨,៩លានដុល្លារសហរដ្ឋអាមេរិក ប្រៀបធៀបទៅនឹងឆ្នាំ២០១៤។

ក្រុមហ៊ុនស្ថាបនា លីមីតធីត បានចូលរួមជាមួយ MARUHAN Japan ASEAN Financial Group ក្នុងខែធ្នូ ឆ្នាំ២០១២ បន្ទាប់ពីបានព្រមព្រៀងដោយធនាគារជាតិនៃកម្ពុជាក្នុងការទិញយកភាគហ៊ុន ៩៥,១% នៅក្នុងក្រុមហ៊ុន ស្ថាបនា លីមីតធីត ដោយធនាគារ MARUHAN Japan Bank Plc.។ ធនាគារ MARUHAN Japan Bank Plc. ដែលជាធនាគារពាណិជ្ជនាំមុខគេមួយក្នុងព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ថា ខ្លួនមានទំនួលខុសត្រូវក្នុងការជួយអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងធានាបានថាប្រជាជនកម្ពុជាអាចទទួលបានផលិតផល និងសេវាកម្មដែលមានគុណភាពល្អដែលពួកគេត្រូវការក្នុងការធ្វើអោយជីវិតរបស់ពួកគេប្រសើរឡើង និងចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសរបស់ពួកគេ។ ការវិនិយោគទុនទៅដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានគឺជាគ្រឹះយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែងរបស់ប្រទេសកម្ពុជា។

ក្នុងឆ្នាំ២០១៦ខាងមុខ ស្ថាបនា លីមីតធីត និងធនាគារម៉ារ៉ូហាន់ជប៉ុន នឹងធ្វើការរួមបញ្ចូលគ្នាដើម្បីបង្កើតជាធនាគារពាណិជ្ជថ្មីមួយ និងបន្តផ្តល់សេវាហិរញ្ញវត្ថុរួមមានឥណទានខ្នាតតូច និងមធ្យម និងផលិតផលធនាគារពាណិជ្ជក្នុងទីផ្សារប្រកួតប្រជែង។ ធនាគារពាណិជ្ជថ្មីដែលមានឈ្មោះ ធនាគារ ស្ថាបនា ភីអិលស៊ី នឹងអាចអោយអតិថិជនខ្លួនទាំងអស់ទទួលបានអត្ថប្រយោជន៍ពីការចែករំលែកសមត្ថភាពផ្ទៃក្នុង ជំនាញ និង ធនធានដែលនឹងអាចផ្តល់សេវាកម្មហិរញ្ញវត្ថុស្តង់ដារខ្នាតអន្តរជាតិទូទាំងប្រទេស និងភ្ជាប់ប្រទេសកម្ពុជាទៅនឹងបណ្តាទីផ្សារពិភពលោក។ ក្រោមការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន MARUHAN Japan ASEAN Financial Group ពួកយើងមានទំនុកចិត្តថា ក្រុមហ៊ុន ស្ថាបនា នឹងបន្តទទួលបានជោគជ័យលើប្រតិបត្តិការមុខជំនួញនៅក្នុងឆ្នាំខាងមុខ ដោយការផ្តល់ជូនផលិតផល និងសេវាកម្មដែលមានលក្ខណៈកាន់តែល្អ

# សារប្រធានក្រុមប្រឹក្សាភិបាល

ប្រសើរដែលអាចធ្វើអោយ ធនាគារ ស្ថាបនា ភីអិលស៊ី ក្លាយជាជំរើសរឹតតែមានភាពទាក់ទាញក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការជួយបង្កើតសហគ្រិនភាព និងធនធានរបស់ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា។

ក្រុមប្រឹក្សារបស់ ធនាគារ ស្ថាបនា ភីអិលស៊ី នឹងបន្តគាំទ្រការគ្រប់គ្រងដើម្បីធ្វើអោយគុណភាពសេវាកម្មកាន់តែល្អប្រសើរជាងមុនធ្វើការប្រើបច្ចេកវិទ្យាទំនើបចុងក្រោយ និងពង្រឹងការគ្រប់គ្រងផ្ទៃក្នុង និងការប្រតិបត្តិតាម។

ក្រុមប្រឹក្សាភិបាលសូមសម្តែងនូវការកោតសរសើរចំពោះការគ្រប់គ្រង និងបុគ្គលិករបស់ ស្ថាបនា លីមីតធីត ទាំងអស់ចំពោះការតាំងចិត្តប្តូរផ្តាច់ និង ការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក។ យើងក៏សូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅទៅដល់អតិថិជនទាំងអស់ម្ចាស់ឥណទាន និងដៃគូពាណិជ្ជកម្មទាំងឡាយសំរាប់ការគាំទ្រមកកាន់បេសកកម្មរបស់យើង និងចំពោះធនាគារជាតិនៃកម្ពុជា ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជាសំរាប់ការផ្តល់ដំបូន្មានការណែនាំ និងការគាំទ្រ។



**បណ្ឌិត ហាន់ ចាងរូ**
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់ប្រធាននាយកប្រតិបត្តិ



**កម្ពុជានៅតែជាទីផ្សារជានាមួយសំរាប់ការធ្វើវិនិយោគ។ រដ្ឋាភិបាល និងវិស័យឯកជនបានសហការគ្នាដើម្បីកែទំរង់សេដ្ឋកិច្ច និងលើកស្ទួយជីវភាពប្រជាជនក្រីក្រប្រកបដោយជោគជ័យ។ ការធានារបស់រដ្ឋាភិបាលសំរាប់សុខសន្តិភាពរបស់ប្រទេសបានផ្តល់ឱកាសអំណោយផលសំរាប់អាជីវកម្មដើម្បីរីកលូតលាស់យ៉ាងលឿន ក៏ដូចជាសំរាប់វិស័យមីក្រូហិរញ្ញវត្ថុ និងអតិថិជនរបស់គេផងដែរ...**

បច្ចេកវិទ្យាថ្មីរបស់វិស័យមីក្រូហិរញ្ញវត្ថុកំពុងបន្តអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា និងកែប្រែជីវភាពប្រជាជនកម្ពុជាយ៉ាងឆាប់រហ័ស និងប្រកបដោយជោគជ័យ។ ការពង្រីកសេវាកម្មហិរញ្ញវត្ថុតាមរយៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្តង់ដារបានរីករាលដាលពាសពេញផ្ទៃប្រទេស ហើយបានផ្តល់ជូនដល់ប្រជាពលរដ្ឋក្រីក្រដែលរស់នៅតាមតំបន់ដាច់ស្រយាលដោយផ្ទាល់ ដែលវាជាចលករជួយក្នុងការអភិវឌ្ឍសង្គមកម្ពុជាអោយរីកចំរើនឡើងយ៉ាងខ្លាំង។

នេះជាបរិបថមួយថ្មីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា លីមីតធីត ចាប់តាំងពីការចូលរួមចំណែកចែករំលែកបេសកកម្មរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន នាដើមឆ្នាំ២០១៣កន្លងមក។ ក្រុមហ៊ុននៅតែបន្តរីកចំរើនជាមួយនឹងបេសកកម្មចាស់របស់ខ្លួន តាមរយៈការផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ និងជំរុញអោយមានសហគ្រិនភាពក្នុងចំណោមប្រជាជនក្រីក្រ ដើម្បីអភិវឌ្ឍខ្លួនរួចចាកផុតពីភាពក្រីក្រយ៉ាងឆាប់រហ័ស។ ក្រុមហ៊ុនធ្លាប់ទទួលបានបទពិសោធន៍រីកចំរើនយ៉ាងខ្លាំងនៅតាមតំបន់ផ្សេងៗ និងក្នុងសហគមន៍នានា និងទទួលបានការគាំទ្រពីសំណាក់អតិថិជនប្រាក់បញ្ញើ-សន្សំយ៉ាងខ្លាំងផងដែរ។

ស្ថេរភាពនយោបាយគឺជាកត្តាដ៏សំខាន់ក្នុងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច។ ការស្រុះស្រួលគ្នារវាងគណបក្សនយោបាយធំៗទាំងពីរគឺជារង្វាន់ដ៏ធំសំរាប់ប្រជាជនកម្ពុជា ដោយវាបាននាំមកវិញនូវសុខសន្តិភាពមកដល់ប្រទេស ហើយធានាបាននូវស្ថិរភាពកំណើនអាជីវកម្មដើម្បីស្ថាបនាសេដ្ឋកិច្ចជាតិគួរអោយកត់សំគាល់។ គិតមកដល់ខែធ្នូ ឆ្នាំ២០១៥ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលអាជ្ញាប័ណ្ណចំនួន៤៨ បានធ្វើប្រតិបត្តិការផ្តល់សេវាកម្ម និងផលិតផលមីក្រូហិរញ្ញវត្ថុរបស់ខ្លួនផ្សេងៗគ្នា ទៅដល់អតិថិជនគ្រប់ស្រទាប់វណ្ណៈនៅគ្រប់២៥ រាជធានី ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយបានផ្តោតទៅលើតំរូវការចាំបាច់របស់អតិថិជននៅតាមជនបទ និងទីប្រជុំជន។ តួនាទីប្រតិបត្តិការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគឺមានគោលដៅជួយលើកស្ទួយជីវភាពរបស់ប្រជាជនក្រីក្រ ដូច្នេះហើយបានជាការិយាល័យរបស់គេត្រូវបានបង្កើតឡើងនៅជិតអតិថិជនដោយប្រជាពលរដ្ឋអាចរកបាននៅតាមថ្នាក់ឃុំ ស្រុក និងខេត្ត។ ទិន្នន័យពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំង ៤៨ បានបង្ហាញថា ការិយាល័យដែលត្រូវបានបង្កើតឡើងសរុបមានចំនួន ១.៣០៨ កន្លែង និងបានផ្តល់ប្រាក់ទុនទៅអោយគ្រួសារចំនួន២.០២២.២៣៥ ដែលមានទឹកប្រាក់ចំនួន ២.៩៥២ លានដុល្លារសហរដ្ឋអាមេរិក និងរក្សាហានិភ័យឥណទានតិចជាង ៣០ថ្ងៃ នៅក្នុងកំរិត០,៦៧%។ ស្ថាបនា លីមីតធីត បានក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំណាប់ថ្នាក់លេខ២ ដែលមានឥណ-ទាន និងប្រាក់បញ្ញើច្រើនជាងគេចាប់តាំងពីឆ្នាំ ២០១៤។ ស្ថាបនាត្រូវបានទទួលស្គាល់ថាជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានឥរិយាបថល្អក្នុងអាជីវកម្ម និងការគ្រប់គ្រងឈានមុខគេក្នុងប្រទេសកម្ពុជា។ គិតមកត្រឹមខែធ្នូ ឆ្នាំ២០១៥ មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨ ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាក្នុងការប្រមូលប្រាក់បញ្ញើ-សន្សំ ហើយក្រុមហ៊ុនទាំងនេះបានប្រមូលប្រាក់បញ្ញើ-សន្សំសរុបបាន ១.៣១៨ លានដុល្លារសហរដ្ឋអាមេរិក ពីអ្នកផ្ញើប្រាក់ចំនួន ១.៤១៨.៧៣២ នាក់។

ស្ថាបនា លីមីតធីត សម្រេចបានបេសកកម្មមុនដំបូងរបស់ខ្លួនក្នុងការពង្រីកការផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុអោយបានដល់គ្រប់ ២៥រាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា និងមានទ្រព្យសម្បត្តិសរុបជាង ៣០០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤។ គិតមកត្រឹមខែធ្នូឆ្នាំ២០១៥ ស្ថាបនា លីមីតធីត

# សាររបស់ប្រធាននាយកប្រតិបត្តិ

សម្រេចបានជោគជ័យយ៉ាងល្អដោយអាចបង្កើនផលបត្រឥណទានក្នុងចំនួន ៥២% និងទឹកប្រាក់សន្សំចំនួន ៥៦% ព្រមទាំងរក្សាគុណភាពឥណទានបានយ៉ាងល្អដោយហានិភ័យឥណទានច្រើនជាង ៣០ថ្ងៃនៅត្រឹមតែ ០,១៦%។ ស្ថាបនា លីមីតធីត បានធ្វើប្រតិបត្តិការលើការិយាល័យសរុបចំនួន១៤៩កន្លែង និងមានបុគ្គលិកបំរើការងារពេញម៉ោងសរុបចំនួន ៣.១២៣នាក់។ អតិថិជនបានកើនដល់ ២៤០.៥៨៤នាក់ ដែលមានទឹកប្រាក់កម្ចីសរុបចំនួន ៤៧២ លានដុល្លារសហរដ្ឋអាមេរិក និងទឹកប្រាក់បញ្ញើសរុបចំនួន ២៦០ លានដុល្លារសហរដ្ឋអាមេរិក។ លទ្ធផលនេះឆ្លុះបញ្ចាំងអោយឃើញអំពីកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លារបស់បុគ្គលិក និងថ្នាក់ដឹកនាំក្នុងការគ្រប់គ្រងដំណើរការអាជីវកម្មរបស់ខ្លួនដែលអាចបង្កើនភាពជឿជាក់ក្នុងទីផ្សារ និងបង្កើនកេរ្តិ៍ឈ្មោះល្អសុសសាយ។ ប្រព័ន្ធប្រតិបត្តិការព័ត៌មានវិទ្យាផ្ទៃក្នុងថ្មី MIS Financial Oracle Flexcube បានគាំទ្រភាពរីកលូតលាស់នេះបានយ៉ាងល្អ ហើយយុទ្ធសាស្ត្ររបស់ភាគទុនិកថ្មី ម៉ារ៉ូហាន់ ធនាគារជប៉ុន ក៏បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងដំណើររីកចំរើននេះផងដែរ។

ស្ថាបនា លីមីតធីត ដែលជាគ្រឹះស្ថានផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដ៏ជោគជ័យមួយ និងដៃគូវិនិយោគ ម៉ារ៉ូហាន់ ធនាគារជប៉ុន អាចសំលឹងឃើញឱកាសក្នុងវិស័យធនាគារដែលនូវតែបើកចំហសំរាប់ភាពជោគជ័យ និងទីផ្សារពេញលេញជាច្រើនទៀត។ ស្ថាប័នទាំងពីរយល់ឃើញថា ប្រសិនបើពួកគេធ្វើការសហការគ្នា នោះក្រុមហ៊ុននីមួយៗនឹងសម្រេចបានបេសកកម្មរបស់ខ្លួនរៀងៗខ្លួន និងអាចជះឥទ្ធិពលខ្លាំងក្លាដល់ដំណើរជោគជ័យរបស់ខ្លួន។ ដូចនេះថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាលរបស់ធនាគារទាំងពីរបានយល់ស្របគ្នាដើម្បីធ្វើការរួមបញ្ចូលគ្នា ក្នុងគោលបំណងអោយកាន់តែមានសក្តានុពលខ្លាំងក្លាជាងមុន។ ការរួមបញ្ចូលគ្នានេះ ស្ថាបនា លីមីតធីត នឹងទទួលបានអត្ថប្រយោជន៍ក្នុងការផ្តល់សេវាកម្ម និងផលិតផលធនាគារពេញលេញ ខណៈពេលដែល ម៉ារ៉ូហាន់ នឹងមានឱកាសប្រើប្រាស់បណ្តាញសាខារបស់ស្ថាបនា លីមីតធីតទូទាំងប្រទេស ដែលជាសក្តានុពលថ្មីសំរាប់ធនាគារក្នុងទីផ្សារប្រកួតប្រជែង។ គំរោងរួមបញ្ចូលនេះក្រោយនឹងបញ្ចប់នាឆ្នាំ២០១៦។ ដូចដែលបានលើកឡើងនៅខាងដើមស្រាប់ ស្ថាបនាសម្រេចបានបេសកកម្មទីមួយ ហើយតទៅមុខទៀតថ្នាក់ដឹកនាំបានយល់ស្របគ្នាដើម្បីកំណត់បេសកកម្មទីពីរបន្តទៀតដែលនឹងនាំធនាគារថ្មីនេះអោយចូលទៅក្នុងឧស្សាហកម្មធនាគារក្របខណ្ឌកំពូលនៅប្រទេសកម្ពុជា ក្នុងរយៈពេល ១០ឆ្នាំក្រោយ។ យើងជឿជាក់ថា ជាមួយបទពិសោធន៍ដែលយើងមានក្នុងអាជីវកម្មជិត ២០ឆ្នាំកន្លងមកនេះ រួមទាំងសក្តានុពលនៃការរួមបញ្ចូលគ្នាថ្មីនឹងអាចធ្វើអោយយើងទទួលបានជោគជ័យតាមផែនការដែលបានកំណត់។ បច្ចុប្បន្ន មានឱកាសជោគជ័យក្នុងទីផ្សារហិរញ្ញវត្ថុ នាឆ្នាំ ២០១៦ខាងមុខ ដែលអាចអនុញ្ញាតអោយអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុបន្តលូតលាស់ និងពង្រីកអាជីវកម្មអោយធំជាងមុន ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងចូលរួមក្នុងការអភិវឌ្ឍជាតិ។ ផលិតផលថ្មីគឺម៉ាស៊ីន ATM ត្រូវបានដាក់បន្ថែមក្នុងឆ្នាំ ២០១៥ ដើម្បីឆ្លើយតបទៅនឹងតំរូវការទីផ្សារ ខណៈពេលដែលសហគ្រិនកម្ពុជាទាំងអស់ត្រៀមខ្លួនរួចរាល់ដើម្បីអភិវឌ្ឍមុខជំនួញរបស់គេ ក្នុងការចាប់ដៃគូជាមួយអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ។

ស្ថាបនា បានរកឃើញនូវឱកាសជោគជ័យនេះ និងប្តេជ្ញាយ៉ាងមុតមាំដើម្បីគាំទ្រដល់តំរូវការដ៏ខ្លាំងក្លានេះ។ ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះដៃគូសហការទាំងអស់ រួមទាំងធនាគារជាតិនៃកម្ពុជា ដៃគូវិនិយោគ ម្ចាស់ឥណទាន ក្រុមប្រឹក្សាភិបាល ភាគទុនិក និងជាពិសេសគឺអតិថិជនស្ថាបនា ដែលបានបន្តគាំទ្រក្រុមហ៊ុនរហូតមក។ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសជូនចំពោះបុគ្គលិក និងថ្នាក់ដឹកនាំសំរាប់ការប្តេជ្ញាចិត្តយ៉ាងមោះមុត ដើម្បីគាំទ្រ និងធ្វើអោយក្រុមហ៊ុនទទួលបានជោគជ័យសំរាប់ឆ្នាំ ២០១៥។



**ឧកញ៉ា បណ្ឌិត ប៊ុន មុនី**

ប្រធាននាយកប្រតិបត្តិ

# ក្រុមប្រឹក្សាភិបាល



**បណ្ឌិត ហាន់ ចាងវូ**, ប្រធានក្រុមប្រឹក្សាភិបាល

បណ្ឌិត ហាន់ ចាងវូ គឺជាអ្នកបង្កើត និងជាប្រធានក្រុមហ៊ុន MARUHAN Corporation ក្នុងប្រទេសជប៉ុន ដែលកំពុងធ្វើការផ្គត់ផ្គង់និងរៀបចំសម្ភារៈកំសាន្តជាច្រើនបែប។ លោកបានបង្កើតក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ១៩៥៧ និងបានធ្វើអោយអាជីវកម្មមួយនេះមានការវិវឌ្ឍន៍យ៉ាងលឿន ដែលបានទទួលចំណូលសាច់ប្រាក់ក្នុងការលក់សរុបជាង ២៥ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ក្រុមហ៊ុន MARUHAN Corporation ត្រូវបានស្គាល់ថាជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យឧស្សាហកម្មក្នុងប្រទេសជប៉ុន។ អាជីវកម្មនៃក្រុមហ៊ុនរបស់លោកមានការរីកចំរើនលូតលាស់ និងទទួលបានជោគជ័យជាបន្តបន្ទាប់ គឺបានមកពីការខិតខំអស់ពីកម្លាំងកាយចិត្តរបស់លោកក្នុងការបំពេញតាមតម្រូវការរបស់អតិថិជន និងស្មារតីប្រកួតប្រជែងខ្ពស់របស់លោក។ បច្ចុប្បន្នលោកកំពុងចូលរួមក្នុងសមាគមន៍មួយចំនួន និងកំពុងបម្រើការជាប្រធានរដ្ឋបាលរបស់ក្រុមហ៊ុន Han Chang-Woo Tetsu Cultural Foundation។ លោកជាប្រធានសមាគមន៍ Kyoto UNESCO Association ជាមន្ត្រីរដ្ឋបាលរបស់សមាគមន៍ Kyoto Chapter United Nations Association of Japan និងជាប្រធាន Tokyo Philharmonic។ សកម្មភាពរបស់លោកក្នុងតួនាទីជាប្រធាន Chang-Woo Han and Nagako Education and Culture Foundation ដែលត្រូវបានបង្កើតក្នុងទីក្រុង Sacheon នៃប្រទេសកូរ៉េខាងត្បូងត្រូវបានទទួលស្គាល់យ៉ាងខ្លាំង។ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ចនយោបាយ ពីសាកលវិទ្យាល័យ HOSEI University ក្នុងឆ្នាំ ១៩៥៣។



**លោក ហាន់ យូ**, អភិបាល

ជាមួយបទពិសោធន៍ជាង ២៣ ឆ្នាំ ក្នុងក្រុមហ៊ុន MARUHAN Corporation នៅប្រទេសជប៉ុន លោក ហាន់ យូ ដែលជាប្រធានក្រុមហ៊ុន និងជាប្រធាននាយកប្រតិបត្តិផ្នែកប្រតិបត្តិការ របស់ក្រុមហ៊ុន MARUHAN Corporation បានដឹកនាំបុគ្គលិក ១៥.០០០នាក់ និងចែករំលែកទស្សនៈវិស័យក្នុងដំណើរការក្រុមហ៊ុន MARUHAN Corporation ដែលជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យសេវាកម្មកំសាន្តលំដាប់ថ្នាក់ពិភពលោក។ លោកបានចូលបំរើការងារក្នុងក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ ១៩៩០។ បន្ទាប់មកលោកបានបំរើការងារក្នុងតួនាទីសំខាន់ៗមួយចំនួនដូចជា នាយកប្រតិបត្តិផ្នែកជំនួញ និងជានាយកគ្រប់គ្រង។ លោកត្រូវបានតែងតាំងជានាយករងក្នុងឆ្នាំ ២០០៦ និងជានាយកក្នុងឆ្នាំ ២០០៨។ លោកបានទទួលសញ្ញាបត្របរិញ្ញាប័ត្រផ្នែកសិល្បៈ ពីសាកលវិទ្យាល័យ HOSEI ក្នុងឆ្នាំ ១៩៨៨។

# ក្រុមប្រឹក្សាភិបាល



**លោក ហាន់ គេន**, អភិបាល

លោក ហាន់ គេន បានចូលរួមជាមួយក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ ២០០០។ ចាប់តាំងពីលោកត្រូវបានតែងតាំងជាអភិបាលក្នុងក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ ២០០៧ កន្លងមក លោកទទួលបន្ទុកផ្នែកគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន MARUHAN Corporation ដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួននៅពាសពេញពិភព-លោក។ លោកក៏បានបម្រើការក្នុងសកម្មភាពក្រុមអាជីវកម្ម នៅតាមបណ្តាប្រទេសអាស៊ានផងដែរ ក្នុងតួនាទីជាអភិបាល និងជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន MARUHAN INVESTMENT ASIA PTE. LTD., ដែលមានការិយាល័យកណ្តាលរបស់ MARUHAN Japan ASEAN Financial Group ស្ថិតនៅក្នុងប្រទេសសិង្ហបុរី។ លោកកំពុងបម្រើការក្នុងតួនាទីជាអភិបាលនៃ ម៉ារ៉ូហាន់ ធនាគារជប៉ុន ដែលជាធនាគារពាណិជ្ជមានអាជ្ញាប័ណ្ណក្នុងប្រទេសកម្ពុជា និងជានាយក MARUHAN Japan Bank Lao ដែលជាធនាគារពាណិជ្ជមានអាជ្ញាប័ណ្ណក្នុងប្រទេសឡាវផងដែរ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យ DOSHISHA ក្នុងឆ្នាំ ១៩៨៧។



**ឧកញ៉ា បណ្ឌិត ប៊ុន មុនី**, អភិបាលប្រតិបត្តិ និង ប្រធាននាយកប្រតិបត្តិ

ជាជនជាតិខ្មែរ កើតនៅឆ្នាំ ១៩៥៧។ លោកបានចូលក្នុងក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ ១៩៩៦ និងត្រូវបានជ្រើសរើសធ្វើជាប្រធានក្រុមប្រឹក្សា ស្ថាបនា ក្នុងឆ្នាំ២០០១។ បច្ចុប្បន្នលោកមានមុខងារជាប្រធាននាយកប្រតិបត្តិ របស់ស្ថាបនា លីមីធីត។ លោកមានបទពិសោធន៍ ២៣ឆ្នាំ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងនោះលោកបានបម្រើការជានាយកប្រតិបត្តិរបស់អង្គការ CCB NGO ចំនួន ៧ឆ្នាំ មុននឹងផ្លាស់តួនាទីជាអគ្គនាយករបស់ CEB ក្នុងឆ្នាំ ២០០១។ លោកជាអ្នកបង្កើត CCB NGO ក្នុងឆ្នាំ១៩៩៥។ លោកបានទទួលសញ្ញាប័ត្រកម្រិតបរិញ្ញាផ្នែករដ្ឋបាលអាជីវកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង សញ្ញាប័ត្រអនុបណ្ឌិតផ្នែករដ្ឋបាលអាជីវកម្ម មកពីសកលវិទ្យាល័យ Ultara ប្រទេសម៉ាឡេស៊ី និងសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែករដ្ឋបាលអាជីវកម្ម មកពីសាកលវិទ្យាល័យ Preston សហរដ្ឋអាមេរិក។ លោកមានជំនាញផ្នែកគណនេយ្យហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រង។

# ក្រុមប្រឹក្សាភិបាល



### **លោក យ៉ាបេ យូស៊ីកាស៊ុ**, អភិបាល

លោក យ៉ាបេ យូស៊ីកាស៊ុ មានបទពិសោធន៍ជាង ៣២ ឆ្នាំក្នុងវិស័យធនាគារ។ ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០០៥ លោកគឺជាអគ្គនាយករបស់ UFJTsubasa Securities Asia ដែលជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន UFJTsubasaSecurities គឺជាធនាគារវិនិយោគនិង Private Banking Vehicle មានទីស្នាក់ការនៅទីក្រុងហុងកុង។ ចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៧ លោកគឺជាមន្ត្រីសាជីវកម្មមួយរូបទទួលបន្ទុកផ្នែកសាជីវកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Mitsubishi UFJ Securities ដែលជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Mitsubishi UFJ Financial Group ។ ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ ២០១៣ លោកបានបំរើការងារក្នុងក្រុមហ៊ុន MU Hands-on Capital (Venture Capital) ក្នុងតួនាទីជាអគ្គនាយក និងប្រធានក្រុមប្រឹក្សាភិបាល។ លោកទទួលបានបរិញ្ញាបត្រផ្នែកពាណិជ្ជកម្ម និងគ្រប់គ្រងនៅក្នុងខែមីនា ឆ្នាំ១៩៧៧ ពីសាកលវិទ្យាល័យ Hitotsubashi លើមុខជំនាញគណនេយ្យគ្រប់គ្រង។ លោកបានចូលរួមជាមួយ Maruhan Japan Bank Plc. នៅក្នុងឆ្នាំ ២០១៤ ក្នុងតួនាទីជាបណ្ណាធិការ និងជាអភិបាលរបស់ធនាគារនេះហើយបន្ទាប់មកលោកបានចូលជាសមាជិកក្រុមប្រឹក្សាភិបាល និងជាសមាជិកគណៈកម្មការក្រុមប្រឹក្សាភិបាលរបស់ស្ថាបនា លីមីតធីតនៅក្នុងឆ្នាំ ២០១៤។



### **លោក ហ្វូជី តាកាស៊ិ**, អភិបាល

លោក ហ្វូជី តាកាស៊ិ បានបំរើការវិស័យហិរញ្ញវត្ថុអស់ ២៩ ឆ្នាំមកហើយ។ លោកបានចាប់ផ្តើមអាជីពរបស់លោកនៅក្នុងឆ្នាំ ១៩៨៧ នៅឯធនាគារ The Bank of Tokyo ហើយបន្ទាប់មកបានផ្លាស់ទៅទីក្រុងឡុងដ៍ក្នុងឆ្នាំ ១៩៨៩ ធ្វើការនៅផ្នែកទំនាក់ទំនងរូបិយបណ្ណអន្តរជាតិ។ លោកបានបំរើការក្នុងតួនាទីជាច្រើនពាក់ព័ន្ធ និងផ្នែកទីផ្សារ និងសាជីវកម្មធនាគារនៅក្នុងធនាគារ The Bank of Tokyo( Mitsubishi )។ ក្នុងឆ្នាំ ២០០១ លោកបានចូលបម្រើការងារនៅ Citibank ក្នុងប្រទេសជប៉ុនដែលមានតួនាទីជាប្រធាន Corporate FX។ លោកបានបំរើការក្នុងមុខតំណែងមួយចំនួនលើផ្នែក FX និងគ្រប់គ្រងទីផ្សារនៅក្នុងក្រុមហ៊ុន Citigroup។ តួនាទីចុងក្រោយបំផុតរបស់លោកមុនពេលបំរើការក្នុងតួនាទីបច្ចុប្បន្ននេះលោកធ្លាប់ជានាយកគ្រប់គ្រងជាសហប្រធាននៃ Global Markets និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិផ្នែកសាជីវកម្មធនាគារនៃ CitibankJapan។ លោកបានទទួលបរិញ្ញាបត្រពីសាកល វិទ្យាល័យ Sophia University ( ប្រទេសជប៉ុន ) និងសញ្ញាបត្រ Chartered Financial Analyst ® designations។

# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ស៊ីណូហារ៉ា កាត្សុហ៊ីរ៉ូ**, អភិបាលឯករាជ្យ

ឯកឧត្តម ស៊ីណូហារ៉ា កាត្សុហ៊ីរ៉ូ ធ្លាប់មានប្រវត្តិជាមួយប្រទេសកម្ពុជាជាង ៤០ឆ្នាំ កន្លងមកហើយ។ មុនពេលដែលលោកបានបម្រើការជាមន្ត្រីលេខាទូតប្រចាំស្ថានទូតជប៉ុននៅកម្ពុជា លោកបានមកដល់ប្រទេសកម្ពុជាមុនដំបូងនៅឆ្នាំ ១៩៦៧ ក្នុងនាមជាមន្ត្រីទូតរបស់ប្រទេសជប៉ុន និងបានចំណាយពេល ២ឆ្នាំ ដំបូងក្នុងវត្តឧណ្ណាលោមក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះលោកបានចំណាយពេល ៧ខែ បួសជាព្រះសង្ឃដើម្បីសិក្សាភាសា និងវប្បធម៌ខ្មែរ។ បន្ទាប់មកលោកបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាចំនួន ២ លើកទៀត ក្នុងនាមអគ្គទីប្រឹក្សាស្ថានទូតជប៉ុន ក្នុងរយៈពេល ៣ ឆ្នាំម្តងៗ (ពីឆ្នាំ ១៩៩១-១៩៩៤ និង ២០០១-២០០៤)។ លោកបានបង្កើតចំណងមិត្តភាពជាមួយប្រទេសកម្ពុជាយ៉ាងរឹងមាំ ដោយបានបម្រើការជាឯកអគ្គរាជទូតជប៉ុន ប្រចាំប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០០៧ រហូតដល់ឆ្នាំ ២០០៩។ បច្ចុប្បន្ន លោកជាអភិបាលឯករាជ្យរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន ហើយលោកក៏ជាអនុប្រធានអង្គការ NGO CIESF Japan (Cambodia International Education Support Foundation) ដែលមានតួនាទីជាប្រធានការិយាល័យតំណាង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានទីតាំងនៅរាជធានីភ្នំពេញ។



**លោក ហ៊ិន មុន្នីវណ្ណ**, អភិបាលឯករាជ្យ

លោក ហ៊ិន មុន្នីវណ្ណ ជាជនជាតិខ្មែរ កើតនៅឆ្នាំ ១៩៧៣។ លោកមានបទពិសោធន៍ជំនាញ ផ្នែកអាជីវកម្មជាង ១៩ឆ្នាំ។ លោកមានទំនាក់ទំនងជិតស្និទ្ធជាមួយបណ្តាក្រុមហ៊ុនក្នុងនិងក្រៅប្រទេស អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីសំខាន់ៗក្នុងជួររដ្ឋាភិបាល។ លោកបានចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ស្ថាបនា លីមីតធីត នៅឆ្នាំ ២០០៦ និងត្រូវបានជ្រើសតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងជាគណៈកម្មការសវនកម្មចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១២។ បច្ចុប្បន្ន លោកជាអគ្គ នាយកក្រុមហ៊ុន All Cambo Products Co., Ltd. និងជាប្រធាន ក៏ដូចជាក្រុមប្រឹក្សារបស់ក្រុមហ៊ុនមួយចំនួនទៀត។ លោកជាអនុប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាប និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមសហគ្រិនវ័យក្មេងកម្ពុជា (Young Entrepreneur Association of Cambodia)។ ក្នុងកំឡុងពេល ៦ ឆ្នាំចុងក្រោយនេះ លោកបានបម្រើការជាតំណាងបុគ្គលិក និងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន សិប្បករអង្គរ (Artisans d’ Angkor) និងបានបម្រើការជាប្រធានផ្នែកហិរញ្ញវត្ថុ របស់គ្រឹះស្ថានទាំងនេះ ក្នុងរយៈពេល ៩ ឆ្នាំចុងក្រោយផងដែរ។ លោកបានចាប់ផ្តើមអាជីពរបស់លោកជាសវនករបឋម និងសវនករជាន់ខ្ពស់អោយ Ernst and Young Phnom Penh រយៈពេល ៣ ឆ្នាំបន្ទាប់ពីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ផ្នែកគ្រប់គ្រង ដែលមានឯកទេសផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យ Maharishi Vedic University ក្នុងព្រះរាជាណាចក្រកម្ពុជាកាលពីឆ្នាំ ១៩៩៧។

# ក្រុមប្រឹក្សាភិបាល



**បណ្ឌិត យ៉ង់ សាំងកុមារ**, អភិបាលឯករាជ្យ

លោកបណ្ឌិត យ៉ង់ សាំងកុមារ កើតនៅឆ្នាំ ១៩៦៦ ក្នុងខេត្តតាកែវ។ បន្ទាប់ពីបញ្ចប់ថ្នាក់ទុតិយភូមិនៅភ្នំពេញក្នុងឆ្នាំ ១៩៨៤ លោកបានបន្តការសិក្សារបស់លោកនៅប្រទេសអាល្លឺមង់។ ក្នុងឆ្នាំ ១៩៩៥ លោកបានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកកសិកម្មមកពីសាកលវិទ្យាល័យ Leipzig នៃប្រទេសអាល្លឺម៉ង់។

លោកបណ្ឌិត យ៉ង់ សាំងកុមារ មានបទពិសោធន៍ ១៦ឆ្នាំ ក្នុងវិស័យកសិកម្ម និង អភិវឌ្ឍន៍ជនបទ ជាពិសេសក្នុងសកម្មភាពស្រាវជ្រាវ កម្មវិធីបំពាក់បំប៉នចំណេះដឹង ការអប់រំ ការបោះផ្សាយ រួមទាំងការគ្រប់គ្រង និងការអភិវឌ្ឍន៍ស្ថាប័នផងដែរ។ ចាប់ពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ១៩៩៧ លោកបានធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុនមានឈ្មោះថា មជ្ឈមណ្ឌលស្ម័គ្រចិត្តជប៉ុនអន្តរជាតិ ហៅកាត់ថា JVC។ បន្ទាប់មកនៅខែ សីហា ឆ្នាំ ១៩៩៧ លោកបានបង្កើតអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះថា មជ្ឈមណ្ឌលកម្ពុជាសម្រាប់ការសិក្សា និងការអភិវឌ្ឍន៍កសិកម្មត្រូវបានស្គាល់ជាទូទៅថា CEDAC ជាអង្គការឈានមុខនៅកម្ពុជាក្នុងវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ។ បច្ចុប្បន្នលោកជាប្រធានអង្គការ CEDAC និងជានាយកនៃសហគ្រាសសេដាក ដែលជាសហគ្រាសសង្គមបានបង្កើតឡើងដោយ CEDAC ក្នុងខែ សីហា ឆ្នាំ២០០៩។ លោកក៏បានជួយបង្កើតសមាគមន៍កសិករជាតិនៅក្នុងឆ្នាំ ២០០៣ ផងដែរ ហើយបច្ចុប្បន្នលោកមានតួនាទីជាទីប្រឹក្សានៃអង្គការនេះ។ ក្រៅពីធ្វើការជាមួយ CEDAC លោកក៏មានតួនាទីជាអភិបាល និងជាក្រុមប្រឹក្សាភិបាលនៃអង្គការក្នុងស្រុកចំនួន ៦ បន្ថែមទៀត។

# ថ្នាក់ដឹកនាំជាន់ខ្ពស់



**ឧកញ៉ា បណ្ឌិត ប៊ុន មុនី**, ប្រធាននាយកប្រតិបត្តិ

ជាជនជាតិខ្មែរ កើតនៅឆ្នាំ ១៩៥៧។ លោកបានចូលក្នុងក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ ១៩៩៦ និងត្រូវបានជ្រើសរើសធ្វើជាប្រធានក្រុមប្រឹក្សា ស្ថាបនា ក្នុងឆ្នាំ២០០១។ បច្ចុប្បន្នលោកមានមុខងារជាប្រធាននាយកប្រតិបត្តិ របស់ស្ថាបនា លីមីធីត។ លោកមានបទពិសោធន៍ ២៣ឆ្នាំ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងនោះលោកបានបម្រើការជានាយកប្រតិបត្តិរបស់អង្គការ CCB NGO ចំនួន ៧ឆ្នាំ មុននឹងផ្លាស់តួនាទីជាអគ្គនាយករបស់ CEB ក្នុងឆ្នាំ ២០០១។ លោកជាអ្នកបង្កើត CCB NGO ក្នុងឆ្នាំ១៩៩៥។ លោកបានទទួលសញ្ញាប័ត្រកម្រិតបរិញ្ញាផ្នែករដ្ឋបាលអាជីវកម្ម ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង សញ្ញាប័ត្រអនុបណ្ឌិតផ្នែករដ្ឋបាលអាជីវកម្ម មកពីសកលវិទ្យាល័យ Ultara ប្រទេសម៉ាឡេស៊ី និងសញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែករដ្ឋបាលអាជីវកម្ម មកពីសាកលវិទ្យាល័យ Preston សហរដ្ឋអាមេរិក។ លោកមានជំនាញផ្នែកគណនេយ្យហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រង។



**លោក លឹម អួន**, អនុប្រធាននាយកប្រតិបត្តិ និងជា ប្រធាននាយកប្រតិបត្តិ ប្រតិបត្តិការ

កើតនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៧៦។ លោកមានបទពិសោធន៍ការងារ ជាង១៧ឆ្នាំ ជាមួយធនាគារពាណិជ្ជ និងក្រុមហ៊ុនសវនកម្មអន្តរជាតិ។ មុនពេលចូលបំរើការងារនៅស្ថាបនា លីមីតធីត លោក លឹម អួន ធ្លាប់បំរើការងារជាសវនករជាន់ខ្ពស់នៅក្រុមហ៊ុនខេភីអឹមជី ចាប់ពីឆ្នាំ១៩៩៧ រហូតដល់ឆ្នាំ ២០០២ ដោយទទួលបាននូវបទពិសោធន៍ផ្នែកសវនកម្មយ៉ាងទូលំទូលាយ រួមទាំងបទពិសោធន៍ការងារនៅប្រទេសម៉ាឡេស៊ី រយៈពេលមួយឆ្នាំផងដែរ។ ក្នុងឆ្នាំ ២០០២ លោកបានចាប់ផ្តើមបំរើការងារនៅធនាគារវឌ្ឍនៈក្នុងប្រទេសកម្ពុជា ដោយត្រូវបានតែងតាំងក្នុងមុខតំណែងជាច្រើនដូចជា អ្នកគ្រប់គ្រងជាន់ខ្ពស់ សាខាកណ្តាល នាយកនាយកដ្ឋានហិរញ្ញវត្ថុ និងរតនាគារ នាយកនាយកដ្ឋានប្រតិបត្តិការ ហើយចុងក្រោយលោកបានកាន់ដំណែងជាអគ្គនាយករងរហូតដល់ពេលលោកសុំលាលែងចេញពីធនាគារនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២។ លោក លឹម អួន បានចូលបំរើការងារនៅស្ថាបនា លីមីតធីត ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ ប្រតិបត្តិការ ក្នុងខែធ្នូ ឆ្នាំ២០១២ ហើយត្រូវបានដំឡើងតួនាទីជាអនុប្រធាននាយកប្រតិបត្តិនាខែសីហា ឆ្នាំ២០១៤ បន្ថែមលើតួនាទីបច្ចុប្បន្នរបស់លោក។

# ថ្នាក់ដឹកនាំជាន់ខ្ពស់



**លោក អ៊ាប ប៊ុនថាន**, ប្រធាននាយកប្រតិបត្តិ ហិរញ្ញវត្ថុ

កើតនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦៥។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែក គ្រប់គ្រងពីសាកលវិទ្យាល័យអន្តរជាតិភ្នំពេញ ប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៧ និងសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចពីវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោកមានបទពិសោធន៍ ២៤ឆ្នាំ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។ លោកបានចាប់ផ្តើមអាជីពរបស់លោកនៅចុងឆ្នាំ ១៩៩២ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុដោយបំរើការជានាយក នាយកដ្ឋានឥណទាន នៅធនាគារកាណាឌីយ៉ា។ ក្នុងឆ្នាំ ១៩៩៥ លោកបំរើការជាមន្ត្រីឥណទាននៅអង្គការ Care International។ នៅឆ្នាំ ១៩៩៦ លោកជានាយកហិរញ្ញវត្ថុនៅ សីលានិធិ (NGO)។ នៅចុងឆ្នាំ ២០០២ លោកបំរើការនៅសមាគមឥណទានប្រាសាក់ក្នុងតួនាទីជានាយកហិរញ្ញវត្ថុ និងនៅឆ្នាំ ២០០៤ លោកត្រូវបានផ្ទេរទៅជានាយករដ្ឋបាលវិញ។ លោកចាប់បំរើការនៅ ស្ថាបនា លីមីតធីត ជានាយក នាយកដ្ឋានហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៦។



**លោក សៀង សេរី**, ប្រធាននាយកប្រតិបត្តិ រដ្ឋបាល

កើតថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៧៣។ លោកទទួលបានសញ្ញាប័ត្របរិញ្ញាបត្រផ្នែក ទីផ្សារពីសាកលវិទ្យាល័យវេទមហាប្ញស្សីក្នុងឆ្នាំ ១៩៩៧ និងសញ្ញាបត្រអនុបណ្ឌិត ផ្នែកគ្រប់គ្រងពីសាកលវិទ្យាល័យ Charles Sturt University ក្នុងប្រទេសអូស្ត្រាលីនាឆ្នាំ២០០៦។ លោកមានបទពិសោធន៍ជាង ១៦ឆ្នាំ ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនិង ក្រុមហ៊ុនចំរុះជាតិសាសន៍ជាច្រើន។ មុនចូលបំរើការងារក្នុងក្រុមហ៊ុនស្ថាបនា លីមីតធីត លោក សេរី បានបំរើការងារជាជំនួយការនាយកប្រតិបត្តិការ និងនាយកសាខានៅអម្រឹតចាប់ពីឆ្នាំ ២០០៤ រហូតដល់ឆ្នាំ២០០៨។ ដោយមានបទពិ-សោធន៍យ៉ាងទូលំទូលាយជាពិសេសលើផ្នែកប្រតិបត្តិការឥណទាន និងគ្រប់គ្រងធនធានមនុស្ស ក្នុងឆ្នាំ២០០៨ លោកបានចាប់ផ្តើមបំរើការងារនៅធនាគារ MARUHAN Japan Bank ដែលជាធនាគារ របស់ប្រទេសជប៉ុនមុនដំបូងបំផុតក្នុងប្រទេសកម្ពុជាក្នុងតួនាទីជាច្រើនរួមមាន ប្រធានសាខា ប្រធានការិយាល័យកណ្តាល ប្រធានផ្នែកលក់ និងចុងក្រោយជាប្រធានស្ថាប័នហិរញ្ញវត្ថុ។ លោកត្រូវបានអញ្ជើញអោយចូលបំរើការងារក្នុងមុខតំណែងជាជំនួយការអគ្គនាយក និងនាយកប្រតិបត្តិទទួលបន្ទុកគ្រប់គ្រងនាយកដ្ឋានពាណិជ្ជកម្ម និងហិរញ្ញវត្ថុរបស់ធនាគារឯកទេសខ្មែរ រហូតដល់ខែកញ្ញា ឆ្នាំ២០១៤។ លោក សេរី បានចូលបំរើការងារនៅក្រុមហ៊ុន ស្ថាបនា លីមីតធីត ក្នុងតួនាទីជា ប្រធាននាយកប្រតិបត្តិ រដ្ឋបាល នាខែតុលា ឆ្នាំ២០១៤។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ ស្ថាបនា លីមីតធីត (“ក្រុមហ៊ុន”) សូមធ្វើការបង្ហាញនូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលរួមជាមួយរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

## ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការ ដោយស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃ ព្រះរាជាណាចក្រកម្ពុជា ហើយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដោយគោរពតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនត្រូវបានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុដែលគ្មានកាលកំណត់ពីធនាគារជាតិនៃកម្ពុជា មានប្រសិទ្ធិភាពពីថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០០៦។ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ក្នុងប្រតិបត្តិការទទួលប្រាក់បញ្ញើ។ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណដែលមានអាយុកាល៣ឆ្នាំមួយផ្សេងទៀតសំរាប់អាជីវកម្មប្តូរប្រាក់។

អាសយដ្ឋានរបស់ក្រុមហ៊ុនដែលបានចុះបញ្ជី គឺនៅអគារលេខ ៨៣១C មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
សេវាកម្មចំបងរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

- ផ្តល់កម្ចីតូចតាច តូច និង មធ្យម
- ផ្តល់សេវាកម្មទទួលប្រាក់បញ្ញើ
- ផ្តល់សេវាកម្មផ្ទេរប្រាក់ក្នុងស្រុក
- ផ្តល់សេវាកម្ម អេធីអឹម (ATM)

## លទ្ធផលប្រតិបត្តិការ

លទ្ធផលហិរញ្ញវត្ថុនៃក្រុមហ៊ុនសំរាប់ឆ្នាំនេះមានដូចខាងក្រោម៖

| | 2015 | | 2014 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ប្រាក់រៀល | ដុល្លារអាមេរិក | ប្រាក់រៀល |
| ចំណេញមុនបង់ពន្ធ | 23,663,795 | 95,838,370 | 13,222,567 | 53,881,960 |
| ពន្ធលើប្រាក់ចំណេញ | (4,723,134) | (19,128,693) | (2,652,770) | (10,810,038) |
| **ចំណេញក្រោយបង់ពន្ធ** | **18,940,661** | **76,709,677** | **10,569,797** | **43,071,922** |

## ភាគលាភ

នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៥ ម្ចាស់ភាគហ៊ុនបានអនុម័ត និងប្រកាសភាគលាភចំនួន ២.៦៤២.៤៤៩ ដុល្លារអាមេរិក នៅក្នុងការិយបរិច្ឆេទ (២០១៤: ១.៥២៣.០១៩ ដុល្លារ)។

## ទុនបំរុង និងសំវិធានធន

មិនមានបំរែបំរួលជាសារវន្តលើទុនបំរុង និងសំវិធានធនសំ-រាប់ការិយបរិច្ឆេទលើកលែងតែបំរែបំរួលដែល ត្រូវបានលាតត្រដាងបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ឥណទានអាក្រក់ និងជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានអាក្រក់ និងសង្ស័យ ត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថារាល់ឥណទានអាក្រក់ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានប៉ាន់ស្មានគ្រប់គ្រាន់សំរាប់ឥណទានអាក្រក់ និងសង្ស័យ។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលអោយចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើបំណុលអាក្រក់ និងសង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្មចរន្ត

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីឈានដល់ការអះអាងថានីតិវិធីពាក់ព័ន្ធជាមួយទ្រព្យសកម្មចរន្ត (លើកលែងតែករណីពាក់ព័ន្ធជាមួយឥណទាន) ដែលទំនងជាមិនអាចទទួលស្គាល់ក្នុងតំលៃដើម ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុននោះ ត្រូវបានកាត់បន្ថយតម្លៃយកស្មើនឹងតម្លៃដែលគេរំពឹងទុកថាអាចទទួលយកបាន។

នៅកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលអាចបណ្តាលអោយការកំណត់តម្លៃនៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានការយល់ច្រឡំ និងមានភាពមិនសមស្របជាសារវន្តនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និងធ្វើអោយប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលនាំអោយមានការយល់ច្រឡំ និងមានភាពមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- គ្មានការទទួលខុសត្រូវដែលកើតចេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន ក្នុងការធានាបំណុលរបស់បុគ្គលដទៃនាការិយបរិច្ឆេទនៃរបាយការណ៍នេះ។
- គ្មានបំណុលយថាហេតុទាក់ទងដល់ក្រុមហ៊ុន ដែលបានកើតឡើងចាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆេទបញ្ចប់ដល់ការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រៅពីបំណុលដែលមានទំនាក់ទំនងជាមួយសកម្មភាពពាណិជ្ជកម្មរបស់ក្រុមហ៊ុននោះទេ។

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល គ្មានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនដែលអាច ឬទំនងក្លាយជាកាតព្វកិច្ចក្នុងអំឡុងការិយបរិច្ឆេទ ១២ខែខាងមុខ បន្ទាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆេទបញ្ចប់នេះនឹងមាន ឬ អាចមានផលប៉ះពាល់ជាសារវន្តលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលទាំងនោះក្លាយជាបំណុលពិត។

## ការប្រែប្រួលនៃហេតុការណ៍

នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនពុំបានដឹងពីហេតុការណ៍ណាមួយ (លើកលែងតែហេតុការណ៍ដែលបានលើកឡើងនៅក្នុងរបាយកាណ៍នេះ ឬក៏របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន) ដែលបានកើតឡើង ហើយធ្វើអោយមានការយល់ច្រឡំជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ធាតុទាំងឡាយដែលមានចរិកលក្ខណៈខុសធម្មតា

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទហិរញ្ញវត្ថុជាសារវន្តមិនត្រូវបានទទួលរងឥទ្ធិពលពីធាតុប្រតិបត្តិការ ឬក៏ព្រឹត្តិការណ៍ណាដែលមានចរិកលក្ខណៈខុសធម្មតានោះទេ។

ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល ពុំមានធាតុប្រតិបត្តិការ ឬ ក៏ព្រឹត្តិការណ៍ណាដែលមានចរិកលក្ខណៈខុសធម្មតាបានកើតឡើងចន្លោះការិយបរិច្ឆេទបញ្ចប់នៃឆ្នាំហិរញ្ញវត្ថុ និងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលទំនងជាមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសំរាប់ឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្នដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ចាប់តាំងពីការិយបរិច្ឆេទតារាងតុល្យការ

ពុំមានព្រឹត្តិការណ៍ជាសារវន្តណាក្រោយការិយបរិច្ឆេទតារាងតុល្យការ ដែលតំរូវអោយមានការគូសបង្ហាញ ឬក៏ធ្វើការកែសំរួលក្រៅពីព្រឹត្តិកាណ៍ដែលបានបង្ហាញភ្ជាប់ជា ស្រេចនៅក្នុងកំណត់បង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុងការិយបរិច្ឆេទនេះនិងនៅកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| Dr. Han Chang-Woo | ប្រធានក្រុមប្រឹក្សាភិបាល (មិនប្រតិបត្តិ) |
| Mr. Han Yu | អភិបាលមិនប្រតិបត្តិ |
| Mr. Han Ken | អភិបាលមិនប្រតិបត្តិ |
| Oknha Dr. Bun Mony | អភិបាលប្រតិបត្តិ និង ប្រធាននាយកប្រតិបត្តិ |
| Mr. Yabe Yoshikazu | អភិបាលមិនប្រតិបត្តិ |
| Mr. Fujii Takashi | អភិបាលមិនប្រតិបត្តិ |
| H.E. Shinohara Katsuhiro | អភិបាលឯករាជ្យ និង មិនប្រតិបត្តិ |
| Mr. Hun Monivann | អភិបាលឯករាជ្យ និង មិនប្រតិបត្តិ |
| Dr. Yang Saing Koma | អភិបាលឯករាជ្យ និង មិនប្រតិបត្តិ |

## សវនករ

ក្រុមហ៊ុនសវនករឯករាជ្យ Ernst & Young (Cambodia) Ltd. ជាសវនករសំរាប់ក្រុមហ៊ុន។

## ភាគកម្មគ្រប់គ្រងរបស់អភិបាល

គ្មានសមាជិកណាមួយនៃក្រុមប្រឹក្សាភិបាល បានកាន់កាប់អត្ថប្រយោជន៍គ្រប់គ្រងនៅក្នុងមូលធននៃក្រុមហ៊ុននោះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនៅការិយបរិច្ឆេទបញ្ចប់នេះ មិនមានកិច្ចព្រមព្រៀងណាមួយ (ក្នុងនោះក្រុមហ៊ុនជាភាគីម្ខាង) ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ អាចបង្កលទ្ធភាពដល់សមាជិកអភិបាលណាម្នាក់អោយទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗដូចជា ការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃ។

ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈហេតុផលនៃកិច្ចសន្យាដែលបានធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលអភិបាលនោះជាសមាជិកក្រុមប្រឹក្សាភិបាល ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានផលប្រយោជន៍ហិរញ្ញវត្ថុជាសារវន្ត លើកលែងតែអត្ថប្រយោជន៍ទាំងឡាយណាដែលត្រូវបានលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## របាយការណ៍ស្តីពី ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងលទ្ធផលនៃប្រតិបត្តិការ ហើយនិងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដែលធ្វើឡើងដោយថ្នាក់ដឹកនាំដែលត្រូវបានតំរូវអោយ៖

- អនុម័តគោលនយោបាយគណនេយ្យសមស្រប ដោយមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល និងប្រុងប្រយ័ត្នហើយត្រូវអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍។
- អនុវត្តតាមបទបញ្ញត្តិ និងសេចក្តីណែនាំដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ឬប្រសិនបើមានគំលាតនៃការអនុវត្តបទបញ្ញត្តិ និងសេចក្តីណែនាំ ហើយនិងស្តង់ដារដែលដើម្បីជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុនោះ គំលាតទាំងនោះគួរតែត្រូវបានលាតត្រដាងព័ត៌មានពន្យល់ និងកំណត់ចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុអោយបានសមរម្យ។
- រក្សាទុកបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និងធានាថាប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឈរលើមូលដ្ឋាននិរន្តរភាព លើកលែងតែក្នុងករណីដែលក្រុមហ៊ុនមិនអាចបន្តសកម្មភាពអាជីវកម្មនាអនាគត។
- បង្កើតគោលនយោបាយទូទៅសំរាប់ក្រុមហ៊ុន អនុម័តរាល់ការសំរេចចិត្ត និងសកម្មភាពទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលដែលមានឥទ្ធិពលលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយនឹងធានាថា គោលនយោបាយនិងការសំរេចចិត្តទាំងនោះត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ថ្នាក់ដឹកនាំជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យដែលត្រឹមត្រូវ ត្រូវបានរក្សាទុក និងលាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអោយបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយនឹងធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ ថ្នាក់ដឹកនាំក៏ជាអ្នកទទួលខុសត្រូវ ក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុន ហើយម្យ៉ាងទៀតក៏ត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ និង ស្វែងរកកំហុសចេតនា និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងក្រុមប្រឹក្សាភិបាលអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដូចដែលមានភ្ជាប់ជាមួយនេះ ដែលបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមបទបញ្ញត្តិ និងសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជានិងស្តង់ដារគណនេយ្យកម្ពុជា។

តំណាងនៃក្រុមប្រឹក្សាភិបាល




Dr. Han Chang-Woo
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៦

# ម្ចាស់ភាគហ៊ុន

ស្ថាបនា លីមីតធីត ត្រូវបានបង្កើតឡើងដោយភាគទុនិក ចំនួនពីរក្នុងឆ្នាំ ២០០៣ : អង្គការស្ថាបនាសហគមន៍កម្ពុជា (CCB NGO) ដែលមានភាគហ៊ុនសរុប ចំនួន ៨១% និង ក្រុមហ៊ុនវិនិយោគបុគ្គលិកស្ថាបនា លីមីតធីត (អតីតក្រុមហ៊ុនបុគ្គលិកស្ថាបនាសហគ្រិនកម្ពុជា លីមីតធីត) ដែលមានភាគហ៊ុនសរុប ១៩%។

នៅដើមឆ្នាំ២០០៥ ក្រុមហ៊ុន ShoreCap International បានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការងារដំផ្ទើមដែល ស្ថាបនា លីមីតធីត បានធ្វើក្នុងរយៈពេល៥ឆ្នាំកន្លងមក ទាក់ទងនឹងការអភិវឌ្ឍន៍សង្គម និងការកាត់បន្ថយភាពក្រីក្រ ហើយបានសម្រេចចិត្តធ្វើជាភាគទុនិកថ្មីជាមួយ ស្ថាបនា លីមីតធីត។ ShoreCap International មិនមែនជាក្រុមហ៊ុនតែមួយដែលបានមកវិនិយោគជាមួយ ស្ថាបនា លីមីតធីតឡើយ។ ដោយមើលឃើញអំពីកិច្ចខិតខំប្រឹងប្រែង និងភាពជោគជ័យដ៏គួរអោយកត់សំគាល់របស់ ស្ថាបនា លីមីតធីត វិនិយោគិនដែលមកពីប្រទេសហូឡង់ដ៏ល្បីឈ្មោះចំនួនពីរគឺ FMO និង Triodos Doen បានចាប់អារម្មណ៍ចំពោះការវិនិយោគនៅក្នុង CEB ហើយក្រុមហ៊ុននីមួយៗបានធ្វើការវិនិយោគ ១៨.៤៧% នៃដើមទុនចុះបញ្ជីសរុបក្នុងឆ្នាំ ២០០៦។

ទោះជាយ៉ាងណាក្នុងខែមេសា ឆ្នាំ២០០៩ ក្រុមហ៊ុន Shore Cap International បានសម្រេចចិត្តចាកចេញពីស្ថាបនា លីមីតធីត និងបានផ្ទេរភាគហ៊ុនទាំងអស់របស់ខ្លួនទៅអោយ ភាគទុនិកថ្មីដែលមានឈ្មោះថា Developing World Market (DWM)។ រចនាសម្ព័ន្ធថ្មីរបស់ម្ចាស់ភាគហ៊ុនរួមមាន៖ CCB NGO មានភាគហ៊ុន ៩.៧៨%, SEI Ltd មានភាគហ៊ុន ១៦.៩២%, DWM FUNDS S.C.A.-SICAV SIF (DWM) មានភាគហ៊ុន ៣៤.៩០%, Stichting Triodos-Doen មានភាគហ៊ុន ១៩.២០% និង Nederlandse Financierings-Maatschappij voor Ontwikkelings-landen N.V.(FMO) មានភាគហ៊ុន ១៩.២០% នៃភាគហ៊ុនសរុប។

នៅដើមឆ្នាំ ២០១២ ភាគទុនិកចំនួនបីដែលមានឈ្មោះថា Developing World Market (DWM), Triodos-Doen និងក្រុមហ៊ុន FMO បានសម្រេចចិត្តចាកចេញពីក្រុមហ៊ុនស្ថាបនា ដោយបានលក់ភាគហ៊ុនទាំងអស់របស់ខ្លួនចេញ បន្ទាប់ពីក្រុមហ៊ុនទាំងពីរមើលឃើញថាស្ថាបនា បានក្លាយជាក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុដ៏រឹងមាំមួយ និងបាននឹងកំពុងធ្វើប្រតិបត្តិការអាជីវកម្មបំរើសេវាកម្មរបស់ខ្លួនជូនប្រជាពលរដ្ឋក្រីក្របានទូទាំងប្រទេសស្របតាមបេសកកម្មរបស់ខ្លួន។

ក្នុងការស្វែងរកដៃគូវិនិយោគថ្មីសំរាប់បន្តធ្វើប្រតិបត្តិការជាមួយក្រុមហ៊ុនស្ថាបនានឹងពង្រីកអាជីវកម្មតាមយុទ្ធសាស្ត្រអាជីវកម្មថ្មី ភាគទុនិកក្នុងស្រុកដែលមាន CCB NGO និង SEI Ltd. បានសម្រេចចិត្តលក់ភាគហ៊ុនរបស់ខ្លួនចំនួន ៤.៨៨% និង ១០០% រៀងគ្នាទៅអោយក្រុមហ៊ុនវិនិយោគថ្មី ដែលមានឈ្មោះថា MARUHAN Japan Bank Plc ដែលត្រូវបានជឿជាក់យ៉ាងមុតមាំថាជាភាគទុនិក ដែលមានសក្តានុភាពក្នុងការគាំទ្រគំពងរីកចំរើន និងការពង្រីកអាជីកម្មរបស់ក្រុមហ៊ុនប្រកបដោយនិរន្តរភាព។ ដំណើរការនៃការផ្ទេរភាគហ៊ុនទៅម្ចាស់ហ៊ុនថ្មី ត្រូវបានបញ្ចប់នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១២ បន្ទាប់ពីទទួលបានការយល់ព្រមពីធនាគារជាតិ នៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម។

ក្នុងឆ្នាំ២០១២ ស្ថាបនាបានផ្លាស់ប្តូរការគ្រប់គ្រងរបស់ខ្លួន ដោយឈានទៅកាន់រចនាសម្ព័ន្ធភាគហ៊ុនថ្មីមួយទៀតគឺ៖ CCB NGO មានភាគហ៊ុន ៤.៩% និង Maruhan Japan Bank Plc មានភាគហ៊ុន ៩៥.១% នៃភាគហ៊ុនសរុប។



# ភាពជាដៃគូ និងបណ្តាញទំនាក់ទំនង

ស្ថាបនា លីមីតធីត ប្តេជ្ញាចិត្តបង្កើតភាពជាដៃគូ និងបណ្តាញឱ្យបានច្រើនដើម្បីសំរេចនូវគោលដៅរួមក្នុងការផ្សព្វផ្សាយឱកាសសំរាប់ស្ត្រីដែលជាសហគ្រិនក្រីក្រ។ ដៃគូរបស់ក្រុមហ៊ុនរួមមានដូចខាងក្រោម ៖

CCB (Cambodia Community Building): ជាអង្គការក្រៅរដ្ឋាភិបាលមួយដែលត្រូវបានបង្កើត ឡើងក្នុងឆ្នាំ ១៩៩៥ ក្នុងគោលបំណងផ្តល់សេវាកម្មហិរញ្ញវត្ថុ និងអប់រំសុខភាពដល់សហគមន៍ក្រីក្រ។ CCB បានកំលាយខ្លួនទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណ និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មក្នុង ខែកុម្ភៈ ឆ្នាំ២០០៣ ក្រោមឈ្មោះថ្មីថា ស្ថាបនាសហគ្រិនកម្មជា លីមីតធីត។ CCB គឺជាស្ថាបនិកមួយរបស់ ស្ថាបនា លីមីតធីត ដែលតែងតែគាំទ្រភាពរីកចំរើនរបស់ក្រុមហ៊ុន។

ប្រជាពលរដ្ឋដែលជាសហគ្រិនក្រីក្រ
គឺជាដៃគូដ៏សំខាន់និងរឹងមាំចាប់តាំងពីការកកើតឡើង នៃ CCB NGO និងក្រោយមកត្រូវបានហៅថា ស្ថាបនា លីមីតធីត។ ស្ថាបនា លីមីតធីត មិនអាចរីកចំរើនក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេបានទេប្រសិនបើគ្មានការជឿទុកចិត្ត និងការគាំ ទ្រពីអតិថិជនរបស់ខ្លួន។

GTZ : បានគាំទ្រ CCB NGO ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបីផ្សេងទៀតក្នុងការចាប់ផ្តើមប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ នៅខេត្តកំពង់ធំក្នុងខែ មីនា ឆ្នាំ ១៩៩៧។ GTZ ក៏បានផ្តល់ជំនួយបច្ចេកទេសមួយចំនួនសំរាប់ដំណើរការនៃការកំលាយខ្លួនពីពាក់កណ្តាលឆ្នាំ២០០១ រហូតមកដល់ ដើមឆ្នាំ ២០០៤ រួមមានការរួមហិរញ្ញប្បទានជាមួយ MPDF.

MPDF (Mekong Project Development Facility):
ផ្តល់ជំនួយដោយ IFC បានគាំទ្រស្ថាបនា ក្នុងដំណើរការកំលាយខ្លួនចុងក្រោយចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០០៣ ដោយផ្តល់ជំនួយបច្ចេកទេសកសាងសមត្ថភាព និងគាំទ្រក្នុងការកេណ្ឌប្រមូលវិនិយោគទុនទ្រព្យសម្បត្តិ និងរយៈពេលវែង។

Blue Orchard: ជាមូលនិធិមីក្រូហិរញ្ញវត្ថុអន្តរជាតិ មានទីស្នាក់ការនៅប្រទេស Switzerland និងជាអ្នកផ្តល់ប្រាក់កម្ចីទីពីរដល់ ស្ថាបនា លីមីតធីត នៅខែមិថុនា ឆ្នាំ២០០៣។

NORFUND: មានទីស្នាក់ការនៅប្រទេស Norway និងបានធ្វើជាដៃគូជាមួយស្ថាបនា នៅក្នុងឆ្នាំ ២០០៧ និងបានផ្តល់ឥណទានអោយស្ថាបនានៅក្នុងឆ្នាំ ២០០៨។

Microfinance Enhancement Facility: មានទីស្នាក់ការនៅប្រទេស Luxembourg និងបានផ្តល់ឥណទានអោយស្ថាបនា ចាប់តាំងពីឆ្នាំ ២០១០។

Triodos Investment Management: ជាធនាគារអភិវឌ្ឍនាំមុខគេមានទីស្នាក់ការនៅប្រទេសហូឡង់ និងជាអ្នកផ្តល់ប្រាក់កម្ចីទីបីដែលផ្តល់ឥណទានដល់ ស្ថាបនា លីមីតធីត នៅក្នុងខែសីហា ឆ្នាំ២០០៣ និងបន្តការផ្តល់ឥណទានតាមតំរូវការ។

Oikocredit: ជាមូលនិធិមីក្រូហិរញ្ញវត្ថុអន្តរជាតិមានទីស្នាក់ការនៅប្រទេសហូឡង់ និងជាអ្នកផ្តល់ប្រាក់កម្ចីទីបួនដល់ស្ថាបនាក្នុងខែសីហា ឆ្នាំ២០០៣ និងបន្តការផ្តល់ឥណទានបន្តបន្ទាប់ក្រោយមកទៀត។

ShoreCap International Ltd. : ជាគំរោងមួយរបស់ធនាគារ Shore Bank អន្តរជាតិ ដែលមានទីស្នាក់ការនៅសហរដ្ឋអាមេរិក។ ក្រុមហ៊ុននេះបានវិនិយោគដើមទុនចុះបញ្ជីជាមួយស្ថាបនា ព្រមទាំងផ្តល់ប្រាក់កម្ចីនៅខែធ្នូ ឆ្នាំ ២០០៤។

ShoreCap Exchange : មានទីស្នាក់ការនៅសហរដ្ឋអាមេរិក។ ក្រុមហ៊ុនបានផ្តល់ជូនស្ថាបនា នូវការគាំទ្រផ្នែកបច្ចេកទេសដើម្បីបង្កើនសមត្ថភាពរបស់បុគ្គលិក និងថ្នាក់គ្រប់គ្រងចាប់តាំងពីឆ្នាំ ២០០៤។

# ភាពជាដៃគូ និងបណ្តាញទំនាក់ទំនង

Novib : ជាមូលនិធិរបស់អង្គការ Oxfam អន្តរជាតិដែលបានផ្តល់ឥណទានដល់ស្ថាបនាក្នុងឆ្នាំ ២០០៥ និងបានជួយចូលរួមក្នុងការផ្តល់ទុនមួយចំនួន សំរាប់ចែករំលែកការចំណាយទៅលើប្រព័ន្ធ software គណនេយ្យថ្មី Micro-Banker for Windows។

BIO : បានផ្តល់ឥណទានដល់ស្ថាបនា ក្នុងខែមីនា ឆ្នាំ២០០៥ ហើយក្រុមហ៊ុននៅតែបន្តផ្តល់ឥណទានបន្ថែមទៀត រហូតដល់ពេលបច្ចុប្បន្ន។

Deutsche Bank (Cayman) Limited: តាមរយៈ Global Commercial Microfinance Consortium Ltd. បានចុះហត្ថលេខាលើកិច្ចសន្យាខ្ចីប្រាក់រយៈពេល៥ឆ្នាំជាមួយស្ថាបនា ដែលបានបើកប្រាក់នៅឆ្នាំ ២០០៦។

GMF (Global Microfinance Facility) : បានចុះបញ្ជីនៅ Cayman Islands និងមានការិយាល័យកណ្តាលនៅលីម៉ា ប្រទេសប៉េរូ។ ក្រុមហ៊ុនបានផ្តល់ប្រាក់កំចីដល់ស្ថាបនានៅក្នុងឆ្នាំ ២០០៧។

Symbiotic SA : បានរៀបចំឡើងក្រោមច្បាប់របស់ប្រទេសស្វីស និងបានផ្តល់ឥណទានអោយស្ថាបនានៅឆ្នាំ ២០០៧។

VDK Spaarbank N.V. : ផ្តល់សេវាធនាគារពាណិជ្ជ។ ធនាគារ VDK Spaarbank N.V. ផ្តល់ឥណទានសំរាប់ពាណិជ្ជកម្ម មុខជំនួញ ឥណទានផ្ទាល់ខ្លួន សេវាបញ្ញើសន្សំ និងសេវាកម្មហិរញ្ញវត្ថុខ្នាតធំផ្សេងៗទៀត។ លើសពីនេះ ធនាគារផ្តល់សេវាធនាគារតាមបណ្តាញអេឡិចត្រូនិច។ VDK Spaarbank N.V. បានបង្កើតឡើងក្នុងឆ្នាំ ១៩២៦ និងមានមូលដ្ឋានក្នុងប្រទេស Belgium។ ធនាគារនេះបានចាប់ដៃគូជាមួយស្ថាបនាក្នុងឆ្នាំ ២០១១។

MARUHAN Japan Bank : ត្រូវបានបង្កើតឡើងក្នុងគោលបំណងគាំទ្រដល់ទំនាក់ទំនងរឹងមាំទ្វេភាគី រវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន ដែលជំរុញអោយមានការធ្វើពាណិជ្ជកម្ម និងការជួយឧបត្ថម្ភគាំទ្រដល់ការបន្តអភិវឌ្ឍរីកចំរើននៃប្រទេសកម្ពុជា។ ធនាគារនេះបានចាប់ដៃគូជាមួយស្ថាបនា លីមីតធីត ក្នុងឆ្នាំ ២០១១។ ម៉ារ៉ូហាន់ធនាគារជប៉ុនបានទិញភាគហ៊ុន ៩៥,១% របស់ស្ថាបនា លីមីតធីត។ ដំណើរការផ្ទេរភាគហ៊ុនត្រូវបានបញ្ចប់នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១២។

ICBC : ជាក្រុមហ៊ុនពាណិជ្ជ និងមានទីស្នាក់ការនៅប្រទេសចិន។ ក្រុមហ៊ុនបានចាប់ដៃគូជាមួយស្ថាបនា លីមីតធីត នៅក្នុងឆ្នាំ២០១៣។

NMI Global Fund : មានទីស្នាក់ការទីស្នាក់ការនៅប្រទេស Norway។ ក្រុមហ៊ុនបានបានផ្តល់ឥណទានអោយស្ថាបនា លីមីតធីត នៅក្នុងឆ្នាំ២០១៣។

ResponAbility SICAV (Lux): ជាក្រុមហ៊ុនវិនិយោគស្ថិតក្រោមច្បាប់របស់ប្រទេស Luxembourg និងមានទីស្នាក់ការនៅប្រទេស Luxembourg។ ក្រុមហ៊ុនបានគាំទ្រដល់ការរីកចំរើនដ៏លឿនរបស់ស្ថាបនា លីមីតធីត ដោយបានផ្តល់ឥណទានក្នុងឆ្នាំ២០១៣។

MIA (Maruhan Investment Asia) : ជាក្រុមហ៊ុនមានអាជ្ញាប័ណ្ណឯកជនមួយ ស្ថិតក្រោមច្បាប់របស់ប្រទេសសិង្ហបុរី និងមានទីស្នាក់ការនៅប្រទេសសិង្ហបុរី។ ក្រុមហ៊ុនបានផ្តល់ឥណទានអោយស្ថាបនា លីមីតធីតក្នុងឆ្នាំ២០១៣។

DEG : ដើម្បីគាំទ្រដល់ភាពរីកចំរើនយ៉ាងលឿន ស្ថាបនា លីមីតធីត បានទទួលកម្ចីពីក្រុមហ៊ុន DEG ជាបន្តបន្ទាប់។ បច្ចុប្បន្ន DEG បន្តផ្តល់កម្ចីដល់ស្ថាបនា លីមីតធីត ផងដែរ។

NEDERLANDSE FINANCIERINGS-MAATSCHAPPIJ VOOR ONTWIKKELINGSLANDEN N.V., (FMO) ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតមួយដែលរៀបចំ និងស្ថិតនៅក្រោមច្បាប់នៃប្រទេសហូឡង់ និងមានការិយាល័យចុះបញ្ជីរបស់ខ្លួននៅ Annavan Saksenlaan 71, 2593 HW

# ភាពជាដៃគូ និងបណ្តាញទំនាក់ទំនង

ទីក្រុងឡាអេប្រទេសហូឡង់។ FMO ជាធនាគារលំដាប់ ថ្នាក់ “AA+/A-1+” ដែលត្រូវបានវាយតំលៃដោយស្ថាប័ន Standard and Poor’s Rating Services ក្នុងឆ្នាំ2014 ហើយជាក្រុមហ៊ុនដែលមានភាគហ៊ុនរដ្ឋាភិបាលហូឡង់ និងក្រុមហ៊ុនឯកជន។ FMO ធ្លាប់ជាភាគទុនិករបស់ ស្ថាបនា លីមីតធីត ចាប់ពីឆ្នាំ2006 ដល់ឆ្នាំ2012 មុនពេលក្រុមហ៊ុនលក់ភាគហ៊ុនរបស់ខ្លួនទៅអោយ ម៉ារ៉ូហាន់ធនាគារជប៉ុន ក្នុងខែវិច្ឆិកា ឆ្នាំ2012។ FMO បានចាប់ដៃគូជាមួយស្ថាបនា ម្តងទៀតក្នុងឆ្នាំ2014 ជាមួយនឹងការផ្តល់កម្ចីរួមមួយដែលមានទឹកប្រាក់ចំនួន 45លានដុល្លារសហរដ្ឋអាមេរិក។ កម្ចីនេះមាន ភាគីម្ចាស់ឥណទានចំនួនបីរួមមាន៖ FMO,OPEC, FINNFUND និង Cordiant។ ឥណទានសរុបនេះត្រូវបានបញ្ចប់នៅឆ្នាំ 2014 និងចំណាយចុងក្រោយបានធ្វើរួចរាល់នៅក្នុងខែមីនា ឆ្នាំ 2015។



# ការត្រួតពិនិត្យអាជីវកម្មផ្នែកប្រតិបត្តិការ

## សមិទ្ធិផលសម្រេចបាន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

### ប្រាក់កម្ចី

គិតត្រឹមបំណាច់ខែធ្នូ ឆ្នាំ២០១៥ ស្ថាបនា លីមីតធីត មានសាខាសរុបចំនួន ១៤៩ ការិយាល័យកណ្តាល។ ប្រតិបត្តិការទាំងមូលបានគ្របដណ្តប់លើ ២៥ រាជធានី/ខេត្ត ១៩៣ ក្រុង/ស្រុក/ ខណ្ឌ ១.៦០៤ ឃុំ/សង្កាត់ និង ១០.២៦៨ ភូមិ។

| បរិយាយ | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|
| ចំនួនអ្នកខ្ចីចងការសរុប | 57,001 | 68,195 | 78,862 | 94,852 | 112,684 |
| កំណើនចំនួនអ្នកខ្ចីចងការ | 30.84% | 19.64% | 15.64% | 20.28% | 18.80% |
| សមតុល្យឥណទាន | 94,665,480 | 121,341,881 | 181,589,769 | 311,393,541 | 472,018,731 |
| កំណើនសមតុល្យឥណទាន | 63.87% | 28.18% | 49.65% | 71.48% | 51.58% |
| ចំនួនអ្នកខ្ចីចងការទទួលបានឥណទានក្នុងឆ្នាំ | 59,903 | 68,668 | 79,074 | 95,036 | 111,347 |
| បរិមាណឥណទានបានបញ្ចេញ | 121,366,900 | 149,776,743 | 216,030,440 | 349,115,416 | 488,011,548 |
| សមតុល្យឥណទានប្រឈមនឹងហានិភ័យ | 207,708 | 473,499 | 381,998 | 482,182 | 736,684 |
| សមតុល្យឥណទានប្រឈមនឹងហានិភ័យជាភាគរយ | 0.22% | 0.39% | 0.21% | 0.15% | 0.16% |

ការបញ្ចេញឥណទាននៅក្នុងឆ្នាំ២០១៥ មានកំណើនខ្ពស់គួរអោយកត់សំគាល់ពោលគឺសមតុល្យឥណទានបានកើនឡើងរហូតដល់ ៥១,៥៨% ចំណែកឯចំនួនអ្នកខ្ចីចងការសរុបបានកើនឡើង ១៨,៨០%។ លទ្ធផលនេះបានកើតចេញពីការពង្រីកបណ្តាញសាខាថ្មីៗជាច្រើនខណៈពេលដែលមានតំរូវការខ្ពស់នៃទីផ្សារ ជាពិសេសកំណើននៃការជឿទុកចិត្តពីសំណាក់សាធារណៈជនទូទៅចំពោះស្ថាបនា លីមីតធីត។

ចំពោះការគ្រប់គ្រងហានិភ័យឥណទានគឺស្ថិតនៅក្នុងស្ថានភាពមួយល្អប្រសើរប្រកបដោយភាពរឹងមាំ ពោលគឺអត្រាសមតុល្យឥណទានដែលប្រឈមនឹងហានិភ័យមានចំនួន ១៦%។ នេះគឺឆ្លុះបញ្ចាំងអំពីភាពរីកចំរើន និងជោគជ័យរបស់អតិថិជនក៏ដូចជាសមត្ថភាពក្នុងការគ្រប់គ្រងឥណទានរបស់ថ្នាក់គ្រប់គ្រង និងបុគ្គលិក។ ទោះបីយ៉ាងណាក៏ដោយដើម្បីធានាបាននូវនិរន្តរភាពនៃគុណភាពឥណទាន ស្ថាបនា លីមីតធីត នៅតែបន្តផ្តល់ជូននូវវគ្គបណ្តុះបណ្តាល និងជំនួយផ្នែកបច្ចេកទេសដល់គ្រប់បុគ្គលិកពាក់ព័ន្ធអោយមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ក្នុងការគ្រប់គ្រងប្រតិបត្តិ-ការឥណទាន។

ហានិភ័យផលប័ត្រ



# ការត្រួតពិនិត្យអាជីវកម្មផ្នែកប្រតិបត្តិការ

## ប្រាក់បញ្ញើ-សន្សំ

យោងតាមតួលេខដែលចេញដោយសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា CMA នាបំណាច់ឆ្នាំ២០១៥ បានបង្ហាញថាចំនួនប្រាក់បញ្ញើសន្សំនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាបានកើនដល់ ១.៣១៨ លានដុល្លារអាមេរិក។ ដោយឡែកប្រាក់បញ្ញើសន្សំរបស់ស្ថាបនា លីមីតធីត បាន កើនឡើងចំនួន ២៥៩.៨៧០.៥៨៩ ដុល្លារអាមេរិក អាស្រ័យដោយសារមានការផ្លាស់ប្តូរនៃផ្នត់គំនិតរបស់អតិថិជនដែលយល់ដឹងច្បាស់អំពីសក្តានុពលនៃប្រាក់បញ្ញើសន្សំ។

សេវាប្រាក់បញ្ញើសន្សំរបស់ស្ថាបនា ទទួលបានភាពពេញនិយមខ្លាំងជាងមុន និងបានក្លាយជាកូនសោសំរាប់ផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានភាពស្រដៀងគ្នាជាមួយនឹងធនាគារ។ គណនីមានកាលកំណត់ និងគណនីបញ្ញើសំចៃ បានកើនឡើងជាលំដាប់ដោយសារកិច្ចខិតខំប្រឹងប្រែងក្នុងការប្រមូលប្រាក់បញ្ញើសន្សំ ដើម្បីពង្រីកផលិតផលបញ្ញើសន្សំរបស់ស្ថាបនា។ ម្យ៉ាងទៀតសេវាប្តូរប្រាក់ត្រូវបានផ្តល់ជូនអតិថិជននូវអត្រាការប្រាក់ប្រកួតប្រជែង ហើយបច្ចុប្បន្នរូបិយប័ណ្ណប្រាក់បាតថៃគឺអាចរកបានផងដែរ។ ផលិតផលបញ្ញើសន្សំផ្សេងៗជាច្រើនបន្ថែមទៀតកំពុងត្រូវបានបង្កើតឡើង និងត្រៀមខ្លួនជាស្រេចសម្រាប់បម្រើជូនអតិថិជនក្នុងពេលខាងមុខរួមមានសេវាទទួលប្រាក់ទូទាត់វិក្កយបត្រ សេវាបើកប្រាក់បៀវត្ស និងគណនីវ័យចំណាស់។

យុទ្ធនាការកេណ្ឌប្រមូលប្រាក់បញ្ញើសន្សំបច្ចុប្បន្នរបស់ស្ថាបនា លីមីតធីត បានធ្វើឱ្យមានកំណើនចំនួនអតិថិជនប្រាក់បញ្ញើសន្សំ និងទឹកប្រាក់បញ្ញើសន្សំកើនឡើងដ៏អស្ចារ្យ។ នាបំណាច់ខែធ្នូ ឆ្នាំ២០១៥ អតិថិជនបញ្ញើសន្សំសរុបបានកើនឡើងពី ៨៧.៥៥២នាក់ មក ១២៧.៩០០នាក់ ជាមួយសមតុល្យប្រាក់បញ្ញើសន្សំសរុបកើនឡើងពី ១៦៦.០៩៦.២៦៨ ដុល្លារអាមេរិករហូតដល់ ២៥៩.៨៧០.៥៨៩ ដុល្លារអាមេរិក។ តួលេខនេះបានបង្ហាញពីកំណើនសមតុល្យប្រាក់បញ្ញើសន្សំរបស់ស្ថាបនាចំនួន ៥៦% ប្រៀបធៀបកាលពីឆ្នាំ ២០១៤។

## ផ្ទេរប្រាក់ក្នុងស្រុក

ដោយសារការយល់ដឹងពីតម្រូវការរបស់អតិថិជន និងអត្ថប្រយោជន៍នៃសេវាផ្ទេរប្រាក់ក្នុងស្រុកអាចជម្រុញអោយការប្រមូលប្រាក់បញ្ញើ-សន្សំសម្រេចដល់ផែនការជាពិសេសផលិតផលនេះអាចជួយកាត់បន្ថយបញ្ហាអសន្តិសុខនៅក្នុងសង្គម ស្ថាបនា លីមីតធីត បានចាប់ផ្តើមផ្តល់សេវាផ្ទេរប្រាក់ (ប្រតិបត្តិការអន្តរសាខា) នេះឡើងចាប់តាំងពីខែតុលា ឆ្នាំ២០០៧។ សម្រាប់អតិថិជនប្រាក់បញ្ញើ-សន្សំអាចផ្ទេរប្រាក់ ដកប្រាក់ និងផ្ញើប្រាក់តាមរយៈគណនីប្រាក់បញ្ញើរបស់ខ្លួនបាននៅគ្រប់ខេត្តក្រុង ដែលមានសេវា ស្ថាបនា លីមីតធីត។ ម្យ៉ាងវិញទៀត អតិថិជនដែលគ្មានគណនីនៅស្ថាបនា លីមីតធីត ក៏អាចប្រើប្រាស់សេវាកម្មផ្ទេរប្រាក់នេះផងដែរ ដោយគ្រាន់តែមានអត្តសញ្ញាណប័ណ្ណតែប៉ុណ្ណោះ។

## សេវា អេ ធី អឹម (ATM)

គំរោងមួយក្នុងចំណោមផែនការយុទ្ធសាស្រ្តទីផ្សាររបស់ស្ថាបនា លីមីតធីត គឺការផ្តល់សេវាកម្មធនាគារតាមប្រព័ន្ធអេឡិចត្រូនិកទំនើបទាន់សម័យ និងមានសុវត្ថិភាពបំផុតសំរាប់អតិថិជន ២៤ ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍។ ដូចនេះនៅក្នុងឆ្នាំ ២០១៥ ក្រុមហ៊ុនបានដាក់អោយដំណើរការដោយជោគជ័យនូវម៉ាស៊ីន ATM ជាង៦០គ្រឿងជាមួយនឹងសេវាកម្មរួមមាន៖ ការដកប្រាក់ ដាក់ប្រាក់ ពិនិត្យសមតុល្យទឹកប្រាក់ ផ្លាស់ប្តូរលេខកូដសំងាត់ បញ្ចូលកាតទូរស័ព្ទ និងផ្ទេរប្រាក់។ បើទោះបីជាម៉ាស៊ីន ATM ជាសេវាថ្មីរបស់ក្រុមហ៊ុន ប៉ុន្តែភាពពេញនិយមនៃប្រព័ន្ធបច្ចេកវិទ្យាទាន់សម័យក្នុងស្រទាប់សង្គមបានធ្វើអោយម៉ាស៊ីន ATM ស្ថាបនា ទទួលការពេញនិយមយ៉ាងខ្លាំង ជាពិសេសពីសំណាក់អតិថិជនប្រាក់បញ្ញើ-សន្សំ។ ក្រុមហ៊ុនគ្រោងនឹងដាក់អោយដំណើរការនូវម៉ាស៊ីន ATM ជាច្រើនគ្រឿងបន្ថែមទៀតក្នុងឆ្នាំ ២០១៦ ដើម្បីបង្កលក្ខណៈអោយកាន់តែងាយស្រួលដល់អតិថិជនរបស់ខ្លួន ដែលនាំទៅរកការពេញចិត្តរបស់អតិថិជនមកលើក្រុមហ៊ុនស្ថាបនាកាន់តែខ្លាំងឡើងជាលំដាប់។

# ការត្រួតពិនិត្យអាជីវកម្មផ្នែកប្រតិបត្តិការ

## បុគ្គលិក និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

### បុគ្គលិក

ដោយការតាំងចិត្តក្នុងការផ្តល់អោយប្រជាពលរដ្ឋក្រីក្រនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជាទទួលបានសេវាកម្មមីក្រូហិរញ្ញវត្ថុរបស់ខ្លួន ក្រុមប្រឹក្សាភិបាលស្ថាបនា លីមីត-ធីត បានសម្រេចចិត្តបើកសាខាបន្ថែមចំនួន ១៣ និងប៉ុស្តិ៍សេវាចំនួន ១០កន្លែងផ្សេងទៀតក្នុងឆ្នាំ ២០១៥។ ធនធានមនុស្សត្រូវបានជ្រើសរើសជាបន្តបន្ទាប់ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជន និងដើម្បីគាំទ្រដល់ការរីកចំរើនយ៉ាងខ្លាំងរបស់ក្រុមហ៊ុន។ ក្នុងឆ្នាំ ២០១៥ ក្រុមហ៊ុន ស្ថាបនា លីមីតធីត មានបុគ្គលិកបំរើការចំនួន ៣.១២៣នាក់ ដែលជាតួលេខកើនឡើងជាងឆ្នាំ ២០១៤ ចំនួន ២៦%។

### ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សជាកត្តាចម្បងដែលទាមទារអោយមានកិច្ចសហប្រតិបត្តិការពីនាយកដ្ឋានពាក់ព័ន្ធទាំងអស់ដើម្បីរក្សាបាននូវសក្តានុពលភាព និងសមត្ថភាពប្រកួតប្រជែងសំរាប់បុគ្គលិក ស្ថាបនា លីមីតធីត ក្នុងការបំរើសេវាកម្មរបស់ខ្លួនជូនប្រជាជនកម្ពុជាទាំងអស់ ជាពិសេសដល់អតិថិជនស្ថាបនាដែលកំពុងប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនស្រាប់។ ដោយយល់ឃើញនូវចំនុចសំខាន់នេះ កម្មវិធីអប់រំក្នុងនិងក្រៅគ្រឹះស្ថានត្រូវបានបង្កើតឡើងសំរាប់បុគ្គលិកគ្រប់លំដាប់ថ្នាក់ និងដល់និស្សិតតាមបណ្តាសាកលវិទ្យាល័យក្នុងខេត្តក្រុងផ្សេងៗគ្នា។ ក្នុងអំឡុងឆ្នាំ ២០១៥ នាយកដ្ឋានធនធានមនុស្សបានផ្តល់មាន កម្មវិធីអប់រំផ្នែកខាងក្រៅចំនួន ៤៥ លើក និងផ្នែក្នុងចំនួន៤៩លើក។ ការអប់រំផ្នែក្នុង គឺជាការហ្វឹកហ្វឺនផ្តល់យោបល់ និងបើកវគ្គបណ្តុះបណ្តាលដែលធ្វើឡើងដោយនយោជិកស្ថាបនាផ្ទាល់ ចំណែកឯកម្មវិធីអប់រំផ្នែកខាងក្រៅរួមមាន សិក្ខាសាលា និងសន្និសីទធ្វើឡើងដោយគ្រូដែលមកពីស្ថាប័នជំនាញផ្សេងៗគ្នា។

### ប្រធានបទនៃកម្មវិធីបណ្តុះបណ្តាលផ្នែកខាងក្រៅរួមមាន

- Supervisory Skills
- Leadership for Managers
- Market Research and Financial Product Development
- Understanding Cambodian Taxation and its Implementation in Responding to Challenges
- Procurement Fraud
- Becoming an Effective Manager
- Internal Auditing Skills for Financial Institutions
- Overview on the Differences between CAS and CIFRS
- Analysis of Financial Performance Indicators for MFI
- Market Research - Qualitative and Data Analysis
- Supervisory Service Skills
- Annual Tax Compliance
- Cambodian Taxation
- Strategic Saving Mobilisation
- Strategies for Managing Liquidity and Interest Rate Risk
- Conflict Management
- The Development of Microfinance Institutions in Cambodia

### ប្រធានបទនៃកម្មវិធីបណ្តុះបណ្តាលផ្ទៃខាងក្នុងរួមមាន

- Customer Service and Sales Techniques
- Deposit Refreshment
- Risk Management and Anti-Money Laundering
- New Staff Training
- Administrative Refreshment Course
- Empowering Leadership
- Branch Management
- Saving Products
- Refreshment for Banknote Counterfeit Detection Training + LMT
- SME Tools
- Refreshment Training for Local Cash Transfer
- Value Chain Financing
- Tax Training Course

# ការគ្រប់គ្រងហានិភ័យ និង ប្រតិបត្តិតាម

ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមត្រូវបានថ្នាក់ដឹកនាំកំពូលរបស់ស្ថាបនា លីមីតធីត ចាត់ទុកថាជាផែនការយុទ្ធសាស្រ្តគន្លឹះមួយសម្រាប់ធ្វើអោយក្រុមហ៊ុនមានភាពរីកចម្រើន និងប្រតិបត្តិការប្រកបដោយស្ថេរភាព។ ថ្នាក់ដឹកនាំកំពូលរបស់ស្ថាបនា លីមីតធីតទទួលស្គាល់ថាវប្បធម៌នៃការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមរឹងមាំនឹងបំពាក់សក្តានុពលភាពដល់ក្រុមហ៊ុនអោយសម្រេចបាននូវគោលដៅអាជីវកម្មជាមួយនឹងកេរ្តិ៍ឈ្មោះល្អប្រសើរក្នុងតំបន់ក៏ដូចជាទីផ្សារអន្តរជាតិ ហើយអាចទទួលបាននូវប្រាក់ចំណេញជាអតិបរមា និងអាចកែតម្រូវបញ្ហាដែលអាចកើតឡើងជាយថាហេតុ និងការប៉ះពាល់ពេលវេលា និងសណ្តាប់ធ្នាប់ក្នុងក្រុមហ៊ុន។

ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្រ្តជាមួយនឹងវប្បធម៌គ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាមប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្ថាបនា លីមីតធីត បានដាក់ចេញនូវក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមចាប់តាំងពីដើមឆ្នាំ ២០១១ មកម្ល៉េះ ដោយរាប់បញ្ចូលទាំងការដាក់ចេញនូវគោលការណ៍នីតិវិធី ឧបករណ៍ និងការបែងចែកតួនាទីនិងទំនួលខុសត្រូវរបស់បុគ្គលិកយ៉ាងច្បាស់លាស់។

ផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមបានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តក្របខណ្ឌរួមមាន ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការប្រឆាំងការលាងសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការប្រតិបត្តិតាម និង វិស្សលប្លូវីង ក្នុងក្រុមហ៊ុនស្ថាបនា លីមីតធីត។ នៅចុងឆ្នាំ ២០១៥ យើងបានសម្រេចគោលដៅជាច្រើនរួមមានៈ

- ក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យត្រូវបានអនុវត្តតាមទាំងស្រុងដោយការិយាល័យកណ្តាល និងគ្រប់សាខាទាំងអស់ដែលហានិភ័យសក្តានុពលទាំងអស់ត្រូវបានកំណត់ឡើង និងកត់ត្រាក្នុងបញ្ជីហានិភ័យ។
- របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ត្រូវបានបញ្ជូនទៅអោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជាអោយបានទៀងទាត់ និងទាន់ពេលវេលាដែលបានកំណត់តាមរយៈប្រព័ន្ធ Reporting System។
- ខណៈពេលដែលយើងនឹងប្រែក្លាយខ្លួនជាធនាគារថ្មីក្នុងឆ្នាំ២០១៦ យើងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធព័តមានក្នុងFlex-cube ដើម្បីអោយត្រូវនឹងតម្រូវការ CAFIU’s។
- ការវាយតម្លៃហានិភ័យលើការប្រឆាំងការលាងសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មត្រូវបានបំពេញដោយជោគជ័យទាន់ពេលវេលា និងបានបញ្ជូនទៅឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ។
-កាតព្វកិច្ចប្រតិបត្តិតាមខាងក្រៅទាំងអស់ត្រូវបានចាត់ចែងយ៉ាងច្បាស់លាស់ ហើយស្ថាបនា លីមីតធីត បានអនុវត្តតាមទាំងស្រុងនូវកាតព្វកិច្ចទាំងអស់នោះ។
- បញ្ជីតាមដាននៃការអនុវត្តកាតព្វកិច្ចខាងក្រៅរបស់សាខាត្រូវបានដាក់ចេញសំរាប់តាមដាននៃកម្រិតប្រតិបត្តិតាមនៅក្នុងស្ថាប័ន។
- គ្មានការបាត់បង់ ឬការរអាក់រអួលគួរអោយកត់សំគាល់ឡើយក្នុងឆ្នាំ ២០១៥ ហើយប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមានលក្ខណៈរឹងមាំ។
- ការផ្តល់យោបល់ទៅលើបញ្ហាដែលទាក់ទងនឹងផ្នែកច្បាប់ត្រូវបានផ្តល់ជូនគ្រប់នាយកដ្ឋាន និងសាខាតាមការស្នើសុំ។
- វគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពត្រូវបានផ្តល់ជូនថ្នាក់គ្រប់គ្រង និងថ្នាក់សាខា។
- ត្រួតពិនិត្យ និងផ្តល់ជំនួយដល់ទីកន្លែងក្នុងការបំពេញកាតព្វកិច្ចទាក់ទងនឹងការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមទាំងកំរិតការិយាល័យកណ្តាល និងកំរិតសាខា។
- វប្បធម៌ដ៏រឹងមាំនៃការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមត្រូវបានពង្រឹងបន្ថែម។
- នីតិវិធីវិស្សលប្លូវីងត្រូវបានរៀបចំរួចរាល់ដើម្បីធានាប្រសិទ្ធភាព ការអោយតំលៃស្មើគ្នា និងការគ្រប់គ្រងគ្រប់ជ្រុងជ្រោយនៅក្នុងស្ថាបនា។
- អនុសាសន៍របស់ធនាគារជាតិនៃកម្ពុជាទាំងអស់ក្នុងឆ្នាំ២០១៤ ត្រូវបានត្រួតពិនិត្យនិងអនុវត្តយ៉ាងល្អិតល្អន់។

ក្នុងឆ្នាំ ២០១៦ ខាងមុខ ស្ថាបនា លីមីតធីត ប្តេជ្ញាចិត្តបន្តអនុវត្តតាមកាតព្វកិច្ចដែលបានកំណត់នានាទាំងអស់ដូចនៅក្នុងឆ្នាំ ២០១៤ ហើយនឹងបន្តអនុវត្តក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាមអោយកាន់តែមានប្រសិទ្ធភាពខ្ពស់។

# សកម្មភាពសង្គម

សកម្មភាពសង្គម គឺជាកិច្ចការមនុស្សធម៌ និងជាក្របខ័ណ្ឌក្រមសីលធ៌មមួយដែល ស្ថាបនា លីមីតធីត បានប្រកាន់ភ្ជាប់សម្រាប់ការចូលរួមនៅក្នុងសុខុមាលភាពសង្គម ដើម្បីបង្កើនកិត្យានុភាពរបស់ក្រុមហ៊ុន និងបង្កើតវប្បធម៌ជួយគ្នាទៅវិញទៅមកផងដែរ។

នៅក្នុងឆ្នាំ ២០១៤ ស្ថាបនា លីមីតធីត បានចូលរួមក្នុងសកម្មភាពសង្គមជាច្រើនដោយក្នុងនោះរួមមាន៖

## ១. ការឧបត្ថម្ភថវិកាជូនកាកបាទក្រហមកម្ពុជា

នាឱកាសនៃទិវាកាកបាទក្រហម អឌ្ឍចន្ទក្រហមពិភពលោកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា លោក លឹម អូន អនុប្រធាននាយកប្រតិបត្តិ ស្ថាបនា លីមីតធីត បានបរិច្ចាគថវិកាចំនួន ៥.០០០ ដុល្លារអាមេរិកជូនទៅដល់កាកបាទក្រហមកម្ពុជា។

ព្រឹត្តិការណ៍នេះត្រូវបានអញ្ជើញចូលរួមជាអធិបតីភាពដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមជាមួយថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការកណ្តាល អ្នកស្ម័គ្រចិត្ត យុវជន មន្ត្រីបុគ្គលិកនៃកាកបាទក្រហមកម្ពុជា និងអ្នកចូលរួមសរុបជាងប្រាំពាន់នាក់។




## ២. ការឧបត្ថម្ភថវិកាដល់មន្ទីរពេទ្យគន្ធបុប្ផា

ជារៀងរាល់ឆ្នាំ ស្ថាបនា លីមីតធីត បានឧបត្ថម្ភថវិការបស់ខ្លួនមួយចំនួនដល់មន្ទីរពេទ្យគន្ធបុប្ផា ដើម្បីចូលរួមក្នុងយុទ្ធនាការរៃអង្គាសប្រាក់របស់មន្ទីរពេទ្យ និងជួយដល់កុមារកម្ពុជា។



# សកម្មភាពសង្គម

## ៣. សិក្ខាសាលាស្តីអំពី "ឱកាសសម្រាប់សហគ្រិនកម្ពុជា និងទីផ្សារអាស៊ាន"

នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ កន្លងទៅ លោក ឧកញ៉ាបណ្ឌិត ប៊ុន មុនី ប្រធាននាយកប្រតិបត្តិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត បានអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាស្តីពី "ឱកាសសម្រាប់សហគ្រិនកម្ពុជា និងទីផ្សារអាស៊ាន"។ កម្មវិធីនេះក៏មានការអញ្ជើញចូលរួមក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រី ឯឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល ឯកឧត្តម ឧកញ៉ាបណ្ឌិត ម៉ុង ឫទ្ធី ឧកញ៉ាបណ្ឌិត ប៊ុន ម៉ុនី និងប្រធាន អគ្គនាយក របស់ស្ថាប័នជាច្រើនទៀត ដើម្បីពង្រឹង និងពង្រីកចំណេះដឹងដល់ប្រធាន បុគ្គលិកក្រុមហ៊ុន អង្គការ និងនិស្សិតកម្ពុជា សរុបប្រមាណជាង ៤០០នាក់។




## ៤. ពិធីបរិច្ចាគឈាមដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម

ក្នុងឆ្នាំ២០១៥ ស្ថាបនា លីមីតធីត បានប្រារព្ធកម្មវិធីបរិច្ចាគឈាមនៅរាជធានីភ្នំពេញ និងនៅខេត្តសៀមរាប សំរាប់មជ្ឈមណ្ឌលជាតិផ្តល់ឈាម ដោយមានការចូលរួមពីបុគ្គលិករបស់ខ្លួនជាង ២០០នាក់។

នេះជាកម្មវិធីបរិច្ចាគឈាមលើកទី៥ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត សំរាប់មជ្ឈមណ្ឌលជាតិផ្តល់ឈាម។



## ៥. កម្មវិធីសិក្ខាសាលានៅសាកលវិទ្យាល័យ គ្រប់គ្រង និង សេដ្ឋកិច្ច

នាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៥ ស្ថាបនា លីមីតធីត សហការជាមួយសាកលវិទ្យាល័យ គ្រប់គ្រង និង សេដ្ឋកិច្ច បានបង្កើតអោយមានកម្មវិធីសិក្ខាសាលាស្តីអំពី "ឱកាសការងារនៅគ្រឹះស្ថាន ស្ថាបនា លីមីតធីត"។ គោលបំណងនៃការបង្កើតកម្មវិធីសិក្ខាសាលានេះគឺដើម្បីផ្សាភ្ជាប់ទ្រឹស្តីបង្រៀននៅក្នុងសាលាទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងស្ថាបនា លីមីតធីត និងណែនាំគន្លឹះមួយចំនួនអោយនិស្សិតរៀបចំខ្លួនអោយបានរួចរាល់ ដើម្បីទទួលបានការងារនៅស្ថាបនា លីមីតធីត បន្ទាប់ពីពួកគេបានបញ្ចប់ការសិក្សា។

# និរន្តរភាពសង្គម និង បរិស្ថាន

## របាយការណ៍សកម្មភាពស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន

ស្ថាបនា លីមីតធីត ប្តេជ្ញាយ៉ាងមុតមាំលើគោលការណ៍នៃការអភិវឌ្ឍដែលមាននិរន្តរភាព។ នៅក្នុងផ្នែកនេះ យើងបានលើកឡើងបញ្ហាដែលពាក់ព័ន្ធនឹងកត្តានិរន្តរភាពសង្គម និងអេកូឡូស៊ីដែលកើតចេញពីប្រតិបត្តិការរបស់ស្ថាបនា លីមីតធីត។ ថ្នាក់គ្រប់គ្រងបាននឹងកំពុងអនុវត្តតាមប្រព័ន្ធគ្រប់គ្រងនិរន្តរភាពសង្គមនិងបរិស្ថាន (ESS) ហើយខិតខំអភិវឌ្ឍជាបន្តបន្ទាប់នៅក្នុងដំណើររបស់ខ្លួនដើម្បីការពារស្ថេរភាពសេដ្ឋកិច្ចសង្គម និងបរិស្ថានសម្រាប់មនុស្សជំនាន់ក្រោយ។

ស្ថាបនា លីមីតធីត យកចិត្តទុកដាក់លើប្រតិបត្តិការមិនត្រឹមតែជាការផ្សារភ្ជាប់ទៅនឹងគោលការណ៍ណែនាំរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការសម្តែងនូវឥរិយាបទបិតថេរមួយផងដែរ។ ស្ថាបនា លីមីតធីត នឹងស្វែងរកប្រតិបត្តិការ និងវិធីសាស្ត្រលើកទឹកចិត្តដែលអាចផ្តល់នូវការរួមចំណែកការពារបរិស្ថានប្រកបដោយភាពវិជ្ជមាន។

## គោលបំណងនៃប្រព័ន្ធគ្រប់គ្រងនិរន្តរភាពសង្គម និងបរិស្ថាន (ESS)

គោលបំណងនៃប្រព័ន្ធគ្រប់គ្រងនិរន្តរភាពសង្គម និងបរិស្ថានគឺដើម្បីផ្តល់នូវគ្រោងការណែនាំសំរាប់ស្ថាបនា លីមីតធីត ដើម្បីអោយស្ថាប័នមានប្រតិបត្តិការប្រកបដោយនិរន្តរភាព និងប្រកបដោយទំនួលខុសត្រូវខ្ពស់ និងមិនមានផលប៉ះពាល់លើបរិស្ថាន និងសង្គម។ ចំណុចបន្ទាប់និងរៀបរាប់អំពីគោលការណ៍ប្តេជ្ញាដែលត្រូវបានរៀបចំឡើងសម្រាប់ស្ថាប័ន និងដំណើរការអភិវឌ្ឍជានិរន្តរន៍។

### បរិស្ថាន

ស្ថាបនា លីមីតធីត មានកាតព្វកិច្ចដ៏ធំជាមួយម្ចាស់ហ៊ុន និងសហគមន៍ដើម្បីធ្វើអោយមានប្រសិទ្ធភាពប្រតិបត្តិការនូវរាល់លទ្ធភាពដែលយើងអាចធ្វើបានសម្រាប់ការរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ រាល់ប្រាក់ទុនមិនគួរត្រូវបានប្រើប្រាស់ដោយការដឹងជាមុន និងចេតនាក្នុងការផ្តល់ឥណទានទៅអោយសហគ្រាសដែលចូលរួមឬពាក់ព័ន្ធ នឹងសកម្មភាពត្រូវបានហាមឃាត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងការកេងប្រវ័ញ្ចលើកំលាំងពលកម្ម ឬពលកម្មកុមារការជួញដូរផលិតផលសត្វព្រៃខុសច្បាប់ ការផលិត ឬជួញដូរសម្ភារៈដែលមានផ្ទុកសារជាតុវិទ្យុសកម្ម ឬសារជាតុគីមីគ្រោះថ្នាក់លើសកំណត់ផ្សេងៗ។

## សូចនាករនៃការបង្ហាញពីការចូលរួមអភិរក្សបរិស្ថាន

### ថាមពល

| ការប្រើប្រាស់ថាមពល | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|
| អគ្គីសនីគិតជាគីឡូវ៉ាត់ម៉ោងក្នុងបុគ្គលិកបម្រើការពេញម៉ោងម្នាក់ | 410 | 418 | 424 | 425 |
| ប្រេងសាំងគិតជាលីត្រក្នុងបុគ្គលិកបម្រើការពេញម៉ោងម្នាក់ | 101 | 99 | 102 | 99 |
| ម៉ាស៊ូតគិតជាលីត្រក្នុងបុគ្គលិកបម្រើការពេញម៉ោងម្នាក់ | 26 | 24 | 25 | 23 |
| ប្រេងរំអិលគិតជាលីត្រក្នុងបុគ្គលិកបម្រើការពេញម៉ោងម្នាក់ | 3.00 | 2.91 | 3 | 2.8 |

ការប្រើប្រាស់អគ្គីសនីក្នុងបុគ្គលិកបម្រើការពេញម៉ោងម្នាក់បានកើនឡើងបន្តិចបន្តួចក្នុងឆ្នាំ ២០១៥ បើប្រៀបធៀបជាមួយឆ្នាំ ២០១៤ ដោយសារមានការពង្រីកនៃប្រព័ន្ធពត៌មានវិទ្យា និងការដាក់អោយប្រើប្រាស់ម៉ាស៊ីនអេធីអឹម។ ការប្រើប្រាស់ប្រេងសាំងសំរាប់បុគ្គលិកពេញម៉ោងម្នាក់មានការថយចុះចំនួន ២,៩ ភាគរយ។ ចំណែកឯការប្រើប្រាស់ប្រេងម៉ាស៊ូត និងប្រេងរំអិលសំរាប់បុគ្គលិកពេញម៉ោងម្នាក់មានការថយចុះចំនួន ៨ភាគរយ និង ៦,៦ ភាគរយរៀងគ្នា។ ការថយចុះនៃការប្រើប្រាស់ប្រេងសាំង ប្រេងម៉ាស៊ូត និងប្រេងរំអិលអាស្រ័យដោយសារមានការបង្កើតសាខាបន្ថែម ហើយភ្នាក់ងារឥណទានធ្វើដំណើរជិតជាងមុន។

### ក្រដាស

| ប្រភេទក្រដាស | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|
| ក្រដាសប្រើប្រាស់គិតជាគីឡូក្រាមក្នុងបុគ្គលិកបម្រើការម្នាក់ | 12 | 11.6 | 14 | 15 |
| ក្រដាសអនាម័យគិតជាគីឡូក្រាមក្នុងបុគ្គលិកបម្រើការម្នាក់ | 0.7 | 0.9 | 0.9 | 1 |
| ក្រដាសចោលគិតជាគីឡូក្រាមក្នុងបុគ្គលិកបម្រើការម្នាក់ | 1.5 | 1.6 | 1.55 | 1.6 |

ការប្រើប្រាស់ក្រដាសក្នុងឆ្នាំ ២០១៥ មានការកើនឡើងសំរាប់បុគ្គលិកម្នាក់ដោយសារមានការបណ្តុះបណ្តាលផ្ទៃក្នុងជាច្រើនត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៥ ចំណែកការប្រើប្រាស់ក្រដាសអនាម័យក៏មានការកើនឡើងបន្តិចដូចគ្នា។

# និរន្តរភាពសង្គម និង បរិស្ថាន

## ទឹក

| ការប្រើប្រាស់ទឹក | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|
| ទឹកក្នុង m3/FTE | គ្មានទិន្នន័យ | គ្មានទិន្នន័យ | 22.3 | 25 |

ការប្រើប្រាស់ទឹកសំរាប់បុគ្គលិកពេញម៉ោងម្នាក់មានការកើនឡើងចំនួន ២៥ម៉ែត្រគូបក្នុងឆ្នាំ២០១៥។

## បុគ្គលិក

| បរិយាយ | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|
| ចំនួនបុគ្គលិក | 1,710 | 2,147 | 2,469 | 3,123 |
| ចំនួនបុរស | 1,149 | 1,463 | 1,666 | 2,085 |
| ចំនួនស្ត្រី | 561 | 684 | 803 | 1,038 |
| ចំនួនបុគ្គលិកធ្វើការពេញម៉ោង | 1,697 | 2,147 | 2,469 | 3,123 |

## វគ្គបំពាក់បំប៉ន

| | | | | |
|---|---|---|---|---|
| បំពាក់បំប៉ននិងការណែនាំបុគ្គលិកថ្មី | 368 | 565 | 681 | 784 |
| បំពាក់បំប៉នដើម្បីអភិវឌ្ឍជំនាញនិងលើកកម្ពស់សមត្ថភាព | 898 | 1,403 | 1,788 | 1,941 |
| ហ្វឹកហ្វឺនសិស្សខាងក្រៅដែលចុះមកធ្វើកម្មសិក្សា | 67 | 84 | 115 | 363 |

ស្ថាបនា លីមីតធីត យកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើជាគំរូដ៏ល្អដោយការផ្តល់ និងអនុវត្តនូវបរិយាកាសការងារដែលមានលក្ខណៈប្រសើរ។ ស្ថាប័នផ្តល់នូវអត្ថប្រយោជន៍មិនត្រឹមតែប្រាក់បៀវត្សប្រចាំខែសមរម្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ប្រាក់សោធននិវត្តន៍ប្រាក់សំរាប់មើលថែសុខភាពមូលនិធិកម្ចីសម្រាប់រាល់បុគ្គលិក ការធានារ៉ាប់រងឧប្បទ្ទវហេតុការងារ និងការគាំពារជាច្រើនផ្សេងទៀត។ បុគ្គលិកអាចជ្រើសរើសអ្នកតំណាងក្រុមរបស់ក្រុមហ៊ុន និងទទួលបានបរិយាកាសការងារប្រកបដោយសុវត្ថិភាព និងសេរីភាព។ ស្ថាបនា លីមីតធីត ផ្តល់នូវឱកាសស្មើភាពនូវរាល់ដំណោះ ស្រាយជាសាធារណៈសម្រាប់អតិថិជននិងបុគ្គលិករបស់ខ្លួន ជាពិសេសតាមរយៈការជ្រើសរើសបុគ្គលិក និងការអភិវឌ្ឍន៍។

ស្ថាបនា លីមីតធីត ផ្តល់តម្លៃដល់បុគ្គលិករបស់ខ្លួនប្រៀបបានទៅនឹងទ្រព្យសកម្មនៃបញ្ញាដ៏មានតម្លៃដែលអាចរួមចំណែកក្នុងដំណើរការការងារដ៏មានប្រសិទ្ធភាពខ្ពស់សម្រាប់ស្ថាប័ន។

